ទៅផែកមើល តែចិត្តមួយទៀតគិតថា ប្រសិនបើកញ្ចប់ក្រ-ដាសនោះមានតម្លៃដូច្នោះមែននោះ នាង ជរី ក៏ត្រូវស្លាប់ ។ ខ្ញុំដាច់ចិត្តសម្លាប់នាងកើតឬ កាលបើនាងជានារីធ្លាប់បានលះបង់អ្វីគ្រប់បែបយ៉ាងបូជាខ្ញុំ ធ្លាប់រួមរស់ជាមួយខ្ញុំ ។ តែចិត្តមួយទៀតគិតទៅដល់អាយុជីវិតនៃប្រទេសជាតិ ... គិតដូច្នេះហើយ ខ្ញុំក៏ដាច់ចិត្តបើកទ្វារចេញទៅជួបនាង ជរី ...

បង! (នាង ជរី ហៅខ្ញុំដោយការភ្ញាក់ ព្រមទាំងឈរស្រឡាំងកាំង) បង ឬ ? (នាងហៅទៀត ហើយក៏ស្ទុះចូលមកឱបខ្ញុំ) ។

- ហ្នឹងហើយបងណា៎ ជរី ... (ខ្ញុំនិយាយ)
- ចុះក្រែងបងស្លាប់បាត់ទៅហើយ ?
- ស្លាប់ក៏ដូចជាពុំស្លាប់ដែរ ។

យ៉ូ-យ៉ាំ ដញី ឈរស្រឡាំងកាំង សំឡឹងមើលមកយើងទាំងពីរនាក់ដោយការងឿងឆ្ងល់ ។ ក្រោយនោះភ្លាម



មួយរំពេច លោកវរសេនីយ៍ទោ មាស-ស្អាត ក៏មកដល់ដែរ ។ លោកក៏ឈរស្រឡាំងកាំង ព្រោះឃើញខ្ញុំឱបនាង ជរី ។ លោកស្ទុះចូលមករកខ្ញុំ ដោយបំណងចង់ប្រទូស-រ៉ាយ ។ ខ្ញុំរុញនាង ជរី ដាក់ចំពីខាងមុខ ។ ពេលនេះខ្ញុំមានចិត្តគិតមួយម៉ឺនមួយសែនចំពូក ។ ខ្ញុំគិតថា ប្រសិនបើខ្ញុំជំរាបការពិតដល់លោក នាង ជរី មុខជាត្រូវស្លាប់ តែប្រសិនបើខ្ញុំពុំជំរាបការពិតដល់លោកទេនោះប្រទេសជាតិក៏ត្រូវស្លាប់ដែរ ។ ក្នុងការដែលនាង ជរី នារីដែលខ្ញុំធ្លាប់រួមរ័កត្រូវស្លាប់ និងការដែលប្រទេសជាតិត្រូវស្លាប់នោះ តើខ្ញុំត្រូវរើសយកខាងណា ខ្ញុំដូចជាពិបាកគិតយ៉ាងខ្លាំង... តែទីបំផុត ខ្ញុំក៏ដាច់ចិត្តថា ស៊ូឲ្យប្រទេសជាតិមានជីវិតរស់នៅទៅចុះ ប្រសើរជាង... ខ្ញុំបានក៏ជំរាបលោកវរសេនីយ៍ទោ មាស-ស្អាត យ៉ាងសុភាព ក្នុងពេលដែលនាង ជរី កំពុងតែសម្រក់ទឹកភ្នែកដាក់ដើមទ្រូងរបស់ខ្ញុំ ជាសក្ខីភាព នៃ ការសំដែងឲ្យដឹងថា

នាងបានផ្ញើអាយុជីវិតលើរូបខ្ញុំ ។

— ព្រះតេជ-គុណ សុំព្រះតេជ-គុណមេត្តាឈប់សិន កុំអាលខឹងនឹងខ្ញុំបាទ សុំមេត្តាផែកបុរសនោះមើលសិន ដើម្បីឲ្យដឹងថា តើវាមានស្នាមនៅក្នុងខ្លួនវា ?

— អញបានបញ្ជាឲ្យឯងសម្ងំផេកនៅឲ្យស្ងៀមក្នុងបន្ទប់ ហេតុអីក៏ឯងចេញមក? ហើយឯងហ៊ានឱប ជរី ទៀតផង...

— ជរី ធ្លាប់ជាប្រពន្ធរបស់ខ្ញុំបាទពានព្រេស / តែជរី... (គ្រាន់តែខ្ញុំនិយាយបានប៉ុណ្ណេះ នាង ជរី ក៏ឱបខ្ញុំយ៉ាងណែន ហើយរុញច្រានទៅខាងក្រោយ ហាក់ដូចជាចង់បិទមាត់ខ្ញុំ ពុំឲ្យខ្ញុំនិយាយ ឯលោកវរសេនីយ៍ទោ មាស-ស្អាត ក៏បើកភ្នែកធំៗ សំឡឹងមើលមកខ្ញុំ ហាក់ដូចជាចង់ដឹងរឿងការអ្វីម្យ៉ាងៗ

— ព្រះតេជព្រះគុណ! សុំព្រះតេជ-គុណ ឆាប់ផែកយួននោះមើលទៅពានព្រេស...

— ផែកវាធ្វើអ្វី ?



ផែនការសម្ងាត់! (ខ្ញុំនិយាយទាំងប្រថុយ ព្រោះពុំដឹងថាគញ្ចប់នោះជាគញ្ចប់អ្វីផង) ផែនការសម្ងាត់បានត្រូវគេលួចយកហើយ ...

គ្រាន់តែឮពាក្យថា ផែនការសម្ងាត់ លោកវរសេនីយ៍ទោក៏ស្ទុះចូលទៅរក យ៉ូ-យ៉ាំងញ៉ី ភ្លាមដោយពុំបានជាប្រុងប្រយ័ត្ន ។ យ៉ូ-យ៉ាំងញ៉ី បានដាល់លោក មាស-ស្អាត មួយដៃចំត្បាមយ៉ាងដំណំ ធ្វើឲ្យលោកដួលប្រូសនៅលើឥដ្ឋ ហើយវាក៏ស្ទុះរត់ចុះទៅតាមជណ្ដើរ ។ ខ្ញុំរលាស់នាង ជរី ចេញ ហើយស្ទុះរត់ទៅជាក់វាមួយជើងចំកញ្ចឹក ធ្វើឲ្យដួលបោកក្បាលទៅនឹងជញ្ជាំងផ្ទះ ហើយវាផ្ទាកមកវិញដួលរមៀលធ្លាក់តាមកាំជណ្ដើរ ខ្ញុំបានជាន់កវាថែមជាប់ពុំឲ្យរមៀលតទៅទៀត ។ លោកវរសេនីយ៍ទោក៏បានក្រោករត់មកជួយចាប់ដែរ តែខណៈជាមួយគ្នានេះ ដបស្រាមួយបានហោះពីខាងលើជម្រង់មកចំក្បាលលោកវរសេនីយ៍ទោ មាស-ស្អាត ។

ខ្ញុំបានប្រាប់លោកចេញឲ្យប្រេតទៅខាងបង្កាន់ដៃជណ្តើរ ។ ឯដបស្រានោះក៏ហោះទៅប៉ះនឹងជញ្ជាំងបែកខ្ចាយ ។ លោកវរសេនីយទោត្រូវតែឡើងទៅចាប់នាង ជរី ទៅខាងលើវិញ ។ ខ្ញុំក៏ចាប់អូស យ៉ូ-យ៉ាំ ជញ៉ យកទៅខាងលើវិញដែរ ។ នៅចំពោះមុខលោកវរសេនីយទោ មាស-ស្អាត ខ្ញុំបានដកយកកញ្ចប់ក្រដាសមួយពីហោប៉ៅអាវ យ៉ូ-យ៉ាំ ជញ៉ ជូនទៅលោក ។ ខ្ញុំបានរាយការណ៍ទាំងអស់ជូនលោកស្តាប់ ។ លោកបានបង្គាប់ឲ្យពួកទាហានដែលនៅខាងក្រោមផ្ទះចាប់ យ៉ូ-យ៉ាំ ជញ៉ និងនាង ជរី ចង ហើយឲ្យនាំយកចេញពីទីនោះទៅ ព្រមទាំងបញ្ជាឲ្យខ្ញុំចូលទៅលាក់ខ្លួនពួនអាត្មានៅក្នុងបន្ទប់ដើមវិញ ។

## វគ្គទី ១៤

# តើចក្រពត្តិបំបែកប្រទេសខ្មែរជាពីរបានឬ ?

ខ្ញុំក៏បេះតែខំប្រឹងសម្ងំនៅស្ងៀម ដើម្បីលាក់ខ្លួនពួនអាត្មានៅក្នុងបន្ទប់ដ៏ស្ងាត់លើគេហដ្ឋានរបស់លោកវរសេនីយទោ មាស ស្អាត តទៅទៀត ដោយពុំដឹងថា ថ្ងៃណានឹងបានរួចខ្លួនបានចេញមុខមាត់នឹងគេ ។ ខ្ញុំនឹករឭកដល់ឪពុកម្តាយបងប្អូននិងនាង យូរ៉េត របស់ខ្ញុំជាខ្លាំង ពល់តែពុំអាចនឹងពណ៌នាបាន ។ ខ្ញុំនឹករហូតដល់មានពេលខ្លះ ខ្ញុំចង់លបទៅជួបនឹងអ្នកទាំងនោះ ស្ទើរតែទ្រាំនៅពុំបាន ។

ថ្ងៃមួយ គឺថ្ងៃទី ១៧ កប់ពីថ្ងៃដែលមានកើតឃាតកម្មនៅលើគេហដ្ឋានរបស់លោកវរសេនីយទោ មាស ស្អាតនោះមក លោកវរសេនីយទោ ក៏បានហៅឲ្យខ្ញុំចេញទៅជួបនឹងលោកនៅខាងក្រៅតែពីរនាក់ ។

– លោក ! (លោកវរសេនីយទោនិយាយ) ខ្ញុំសុំ

សរសើរលោកដោយស្មោះស្ម័គ្រ ក្នុងការដែលលោកបំពេញបេសកកម្មពិសេសជូនចំពោះជាតិមាតុភូមិ ហើយឯកឧត្ដមទេសរដ្ឋមន្ត្រីក្រសួងការពារប្រទេស ក៏បានផ្ដាំផ្ញើឲ្យខ្ញុំសំដែងនូវអំណរគុណចំពោះលោកផងដែរ ។

— ព្រះតេជ-គុណ ! បើអញ្ចឹងបេសកកម្មរបស់ខ្ញុំបាទបានត្រូវចប់ហើយឬ ? ហើយខ្ញុំបាទអាចចេញមុខមាត់បានហើយឬតានក្រោស ?

— ហ្នឹងហើយ ! លោកអាចចេញពីទីនេះបាន ប្រសិនបើលោកចង់ចេញ តែលោកកុំអាលប្រញាប់បង្ហាញមុខមាត់ឲ្យគេឃើញច្រើនពេក ព្រោះក្រែងមានគ្រោះថ្នាក់ដល់រូបលោកនៅថ្ងៃក្រោយ ។

— បើអញ្ចឹង ខ្ញុំបាទអាចចេញទៅជួបមុខឪពុកម្ដាយរបស់ខ្ញុំបាទបានឬទេតានក្រោស ?

— បាន ! លោកអាចទៅជួបឪពុកម្ដាយលោកបាន តែ



សុំលោកទៅជួបយ៉ាងស្ងាត់ៗ កុំឲ្យគេឃើញច្រើនពេក ហើយខ្ញុំសុំផ្ដាំលោកថា បើលោកអាចលាក់ខ្លួនពួនអាត្មាឲ្យបានយូរតទៅទៀតនោះ ក៏ជាការប្រសើរណាស់ដែរ ...

តពីនោះមក លោកវរសេនីយ៍ទោមាស ស្អាត បាននិយាយរឿងរ៉ាវពិតឲ្យខ្ញុំស្ដាប់ដូចតទៅ ៖

ពួកសេ-អាតូ ដែលមានអាមេរិកាំងជាមេក្លោង ចង់សម្លាប់ប្រទេសខ្មែរយើង ដែលប្រកាន់យកនូវមាគ៌ានយោបាយអព្យាក្រឹត ក្រោមព្រះរាជកិច្ចដឹកនាំនៃសម្ដេចព្រះនរោត្ដម សីហនុ ប្រធានចលនាសង្គមរាស្ត្រនិយម ពង្រីកពង្រឹងជាតិ ហើយពុំព្រមចុះចូលជាមួយនឹងពួកគេ ។ គេបានណែនាំសៀមនិងយួនខាងត្បូង ឲ្យពន្យុះវត្តជាកញ្ចះរបស់គេគឺ ថាញ់-សារី និងឈួន ឲ្យបង្កបង្កើតជាបក្ស ដោយមានពួកគេគាំទ្រជួយពីខាងក្រោយ នូវគ្រឿងសព្វាវុធយុទ្ធោបករណ៍ជាច្រើនផង ។ ក្រុមចារកម្មរបស់យើងបាន

សើុបការដឹងច្បាស់ថា ឈ្នួ ឆ ប្រុងក្បត់វាយដណ្ដើមយកខេត្ត សៀមរាប-កំពង់ធំ និងបាត់ដំបង ហើយប្រកាសធ្វើជារដ្ឋខ្មែរ សេរី ដើម្បីវាយដណ្ដើមយកអាណាចក្រកម្ពុជាទាំងមូលតទៅ ទៀត ពួកយើងបានសើុបដឹងច្បាស់ដល់ពេលវេលាដែលវា បានកំណត់ទុក ។ ដើម្បីបំពានគំនិតរបស់ពួកវា ឯ.ឧ. ទេស រដ្ឋមន្ត្រីក្រសួងការពារប្រទេស លោក ហង្ស-ចិរើង និង រូបខ្ញុំ បានសំរេចចិត្តថា យើងត្រូវប្រើកលល្បិចក្នុងរឿងនេះ គឺត្រូវរៀបចំផែនការសម្ងាត់មួយ ដើម្បីវាយតទប់នឹងពួកវា រួចហើយយើងត្រូវរកវិធីធ្វើឲ្យវាដឹងថា យើងប្រើវិធីនេះ តែ លឿនពេលជាងពួកវាមួយថ្ងៃ ដើម្បីឲ្យពួកវាត្រេកចិត្ត ដ្បិតវា យល់ថា ផែនការរបស់វាបានត្រូវពួកយើងដឹង ហើយពួក យើងក៏មានផែនការទប់ទល់ កាលបើពួកវាបានដឹងដូច្នេះ ហើយពួកវាមុខជាប្ដូរផែនការថ្មីយកមកប្រើទៀត ដើម្បីកុំឲ្យ ពួកយើងយកផែនការតទប់របស់យើងនោះទៅប្រើកើត ។



ប៉ុន្តែតាមពិត ពួកយើងធ្វើដូច្នេះ ក៏គ្រាន់តែជាការបង្វែងដាន វាតែប៉ុណ្ណោះ ព្រោះយើងធ្វើឲ្យពួកវាដឹងទៀតថាផែនការ តទប់របស់ពួកយើងនោះ បានត្រូវពួកវាដឹងហើយៗ ពួកយើង នឹងពុំប្រើផែនការនោះដែរ ។ ដូច្នេះហើយ បានជាអគ្គសេនា ធិការនៃកងយោធពលខេមរភូមិន្ទរបស់យើង ត្រូវការរូប លោកឲ្យដើរតួជាអ្នកក្បត់ជាតិ លួចយកផែនការសម្ងាត់របស់ យើងនោះទៅលក់ឲ្យពួកវា ដើម្បីធ្វើឲ្យពួកវាបានដឹងនូវផែន ការនោះ ។ តែក្រោយមកយើងធ្វើជាចាប់យកលោកទៅ ប្រហារជីវិត ជាលោកក្បត់ជាតិ ដោយលួចយកផែនការ សម្ងាត់របស់ពួកយើងទៅលក់ឲ្យពួកវា ដើម្បីបង្វែងដានពួក វាថាផែនការសម្ងាត់របស់ពួកយើង ត្រូវបានដឹងទៅដល់ពួក វាហើយៗ យើងនឹងលែងប្រើផែនការនោះ ។ តែតាមពិត យើងយកផែនការនោះទៅប្រើដដែល គ្រាន់តែប្រើមុនពេល កំណត់បីថ្ងៃតែប៉ុណ្ណោះ ។ ដោយសារការដែលពួកយើង

ធ្វើដូច្នេះ ពួកយើងក៏បានទទួលនូវជោគជ័យជាទីពេញចិត្ត ។

ខ្ញុំបានសួរលោកវរសេនីយ៍ទោ ពីរឿងឆាង ជរី និង យ៉ូ-យ៉ាំងជញ៉ លោកបានមានប្រសាសន៍ថា :

រូបលោកបានទទួលភារៈត្រូវពាក់ព័ន្ធ រៀបចំនូវអក្សរកូនសោសម្ងាត់ សម្រាប់ប្រើប្រាស់ក្នុងកងទ័ពជាតិរបស់យើង ពួកវាដឹងដូច្នោះ ក៏បញ្ជូនអ្នកទាំងពីរនេះឲ្យមកធ្វើល្បិចកល លួចយកអក្សរកូនសោសម្ងាត់នោះ ទៅពិនិត្យមើលមួយជាន់ទៀត ។

ទីបំផុត លោកបាននិយាយរៀបរាប់ពីជោគជ័យ នៃល្បិចកិច្ចកលរបស់កងទ័ពយើងថា : កងទ័ពរបស់យើងបានវាយប្រហារខ្មាំងបានជ័យជំនះយ៉ាងស្រួល ព្រោះវាមិនដឹងខ្លួន ។ លោកបានបញ្ជាក់ថា ទាហានយើងបានចាប់បាន ប៉ុស្តិ៍វិទ្យុ និង អ្នកបច្ចេកទេសយួនពីរនាក់ ដែល ដៅ ត្រុង ហ៊ីវ អ្នកតំណាងយួនខាងត្បូងបាននាំមក ដោយបន្លំឈ្មោះជាចិន



កំពុងតែប្រតិបត្តិការក្បត់ជាមួយ ស្វ៉ាយ៉ា-ឈយ ប៉ ឈិតជាប្អូនបង្កើតរបស់ឈួន ព្រមទាំងមាសចំនួនជាងពីររយគីឡូផង ៗ ចំណែក ដាប-ឈួន វាបានរត់ចេញទៅតែខ្លួនមួយបាត់ ហើយក៏ត្រូវពួកទាហានយើងដេញទាន់ សម្លាប់បានទៅស្រណុយទៅ ។

លោកបានបញ្ជាក់ថា ដាប-ឈួន សម-សារី ហ៊ានធ្វើដូច្នេះ មកពីសំអាងដល់ការធានាគាំទ្រនៃឧត្តមនាវីអាមេរិកាំងនាម ហ្វិល្ត (Amiral Felt) នៃឧត្តមសេនីយ ឡាវសុន កុល ឡាំង (Général Lawson - Collins) នៃវរសេនីយឯក ឡង់ស្ដាល (Colonel Landsdale) នៃឧត្តមនាវីហុបវុត (Amiral Hopwood) និងនៃលិខិតរបស់លោកប្រធានាធិបតី អាយស៊ិនហូវ័រ (Eisenhower) ដែលអះអាងនូវគំរោងការក្បត់កំចាត់សម្ដេច ព្រះឧបេក្ខម ស៊ីហនុ និងអព្យាក្រិតភាពខ្មែរ ធ្វើជាសាធារណរដ្ឋកម្ពុជាសេរីមួយថ្មី ។

ខ្ញុំបានជំរាបលាលោកវរសេនីយ៍ទោ មាស-ស្អាត ទៅរកឪពុកម្ដាយខ្ញុំ ក្រោយដែលលោកបាននិយាយរឿងរ៉ាវចប់សព្វគ្រប់ហើយ ។

– សុំឲ្យបានសេចក្ដីសុខចំរើន! (លោកឲ្យពរសព្វសាធុការដល់ខ្ញុំ ព្រមទាំងហុចកញ្ចប់មួយឲ្យខ្ញុំ) នេះជាប្រាក់មួយសែនរៀល ដែលអគ្គសេនាធិការរបស់យើង បានឲ្យជារង្វាន់ដល់លោក – សុំលោកយកទៅចាត់ចែង តាមការត្រូវការ ហើយលោកនឹងត្រូវបានឡើងសក្តិជាអនុសេនីយ៍-ឯក ប៉ុន្តែលោកអាចឈប់សំរាក ៦ ខែ ឬ ១ ឆ្នាំសិនចុះ ទំរាំពេលណាដែលអគ្គសេនាធិការត្រូវការរូបលោក សុំគេហៅមក ...

ខ្ញុំបានទទួលយកកញ្ចប់ប្រាក់នោះពីដៃលោក ហើយក៏លាលោកម្ដងទៀត ។

ខ្ញុំបានជិះគ្រឿងក្រយានសំរាប់ទៅផ្ទះខ្ញុំ ។ ខ្ញុំមើល



នាឡិកាដៃឃើញម៉ោង ២២ ហើយ ខ្ញុំនឹកអរព្រួច ព្រោះពេលថ្មើរនេះជាពេលស្ងាត់ ដែលខ្ញុំអាចលបទៅជួបនឹងឪពុកម្ដាយរបស់ខ្ញុំបានដោយស្រួល ព្រោះបងប្អូននិងក្មួយៗ គេដេកលក់អស់ហើយ ។

ខ្ញុំបានចូលទៅជួបនឹងម្ដាយរបស់ខ្ញុំ ដែលកំពុងតែអង្គុយសូត្រធម៌ក្នុងទីងងឹតតែម្នាក់ឯង ។ ម្ដាយខ្ញុំភ្ញាក់ព្រើតរៀបនឹងស្រែកឡូឡាឡើង ដោយការភិតភ័យព្រោះលោកគិតថាជាខ្មោចបិសាចរបស់ខ្ញុំទៅលងលោក តែខ្ញុំនិយាយកាត់ទាន់

– ម៉ែ! សុំម៉ែកុំភិតភ័យអ្វី.. ខ្ញុំមកវិញហើយ!

– កូន! កូនឬ?... (ម្ដាយរបស់ខ្ញុំនិយាយតែប៉ុណ្ណោះ ហើយក៏ឱបខ្ញុំជាប់)

– បាទខ្ញុំ!... ខ្ញុំមកវិញហើយ...

– ចុះក្រែងកូនស្លាប់ហើយ...?

– ទេម៉ែ! កូននៅពុំទាន់ស្លាប់ទេ... ចុះប៉ានៅឯណា

– ទុះ ! ... នៅឯក្នុងឯណោះ ។

ម្ដាយខ្ញុំគិតក្រោកទៅបើកភ្លើងអគ្គិសនីបំភ្លឺ តែខ្ញុំបាន សុំកុំឲ្យបើក ព្រោះក្រែងពួកក្មេងៗភ្ញាក់ដឹង ជាហេតុនាំឲ្យ បែកការ ។ ម្ដាយខ្ញុំបានដឹកដៃខ្ញុំទាំងទឹកភ្នែកទៅរកឪពុកខ្ញុំ នៅឯក្នុងបន្ទប់ ។

ខ្ញុំពុំអាចនឹករកពាក្យណា យកមកសរសេរឲ្យសមតាម សេចក្ដីត្រេកអរនៃឪពុកម្ដាយរបស់ខ្ញុំ នៅពេលដែលលោក បានជួបមុខខ្ញុំវិញ ព្រោះលោកបានគិតថាគ្មានសង្ឃឹមនឹងបាន ជួបនោះឡើយ ។ ខ្ញុំសង្កេតឃើញលោកទាំងពីរនិយាយ មករកខ្ញុំ ដោយការប្រោសប្រណីដែលមានទឹកភ្នែកជាសក្ខីភាព នៃសេចក្ដីមេត្តាករុណា ។

យប់នេះ យើងស្ទើរតែពុំបានដេក ព្រោះរវល់តែសំណេះ សំណាលរឿងផ្សេងៗក្នុងជីវិត ដែលមើលទៅម្ដាយខ្ញុំដូចជា និយាយច្រើនជាងគេ ព្រោះលោកចេះតែចង់ដឹងពុំចេះអស់



ពុំចេះហើយសោះ ។

នៅយប់ទីពីរ ខ្ញុំបានលបទៅជួបនឹង សុ១.សម្បូរ ដែលជាមិត្តសំឡាញ់ស្មើដោយជីវិតរបស់ខ្ញុំ ដើម្បីសាកសួរ ដំណឹងពីនាង យូរ៉េត នារីជាទីស្នេហារបស់ខ្ញុំ ។

ខ្ញុំស្រងាកចិត្ត នៅពេលដែលបានឮសុ១-សម្បូរ និ- យាយប្រាប់ថា គេបានទទួលសំបុត្រមួយច្បាប់ពីនាង យូរ៉េត ក្រោយពេលដែលខ្ញុំត្រូវគេយកទៅប្រហារជីវិត ប្រហែលជា ប្រាំពីរប្រាំបីថ្ងៃ ។ ក្នុងសំបុត្រនោះ នាងបានសរសេរ រៀបរាប់យ៉ាងវែងឆ្ងាយពីជីវិតអកុសលរបស់នាងដែលគ្មានទីពឹងទី សង្ឃឹម ។ នាងបានសុំលាគេដោយគ្មានថ្ងៃសង្ឃឹមថានឹង បានឃើញមុខគ្នាទៀត ដោយនាងត្រូវដើរផ្សងព្រេងទៅរក កន្លែងថ្មី ហើយនាងបានជូនសួនឲ្យវិញ្ញាណក្ខន្ធរបស់ខ្ញុំ ដែល នាងជឿជាក់ថា ខ្ញុំស្លាប់មែននោះ ទៅនៅរង់ចាំនាងនាជាតិ ខាងមុខ ។

សុខ-សម្បូរ បានខំលើកកកាយរកសំបុត្ររបស់នាង យូរ៉េត នោះយកមកឲ្យខ្ញុំអានដែរ តែរកពុំឃើញសោះ ព្រោះពុំដឹងជាគេប្រឡំដៃទុកនៅត្រង់ណា ។

សុខ-សម្បូរ ក៏ដូចជាខ្ញុំដែរ យើងបានសន្និដ្ឋានថា នាង យូរ៉េត ពេលនេះមុខជាចេញផុតពីភូមិ ពោធិហ្មស្ត្រី ទៅហើយ តែថានាងទៅនៅឯណានោះ ក៏ជាការពិបាកនឹងដឹងដល់ដែរ ។

សេចក្ដីទុក្ខក្រៀមក្រំបានគ្របសង្កត់លើបេះដូងរបស់ខ្ញុំយ៉ាងធ្ងន់ ។ ខ្ញុំគិតថា ការដែលនាង យូរ៉េត ដើរចេញលែងនៅស្រុកពោធិហ្មស្ត្រីនោះ ព្រោះនាងជឿជាក់ថា ខ្ញុំស្លាប់ពិតប្រាកដមែនទុះឯង ។

ខ្ញុំបានលា សុខ-សម្បូរ ត្រឡប់ទៅផ្ទះវិញទាំងក្រៀមក្រំ ។ នៅតាមផ្លូវ ខ្ញុំចេះតែនឹកស្រមៃដល់នាង យូរ៉េត ។ ខ្ញុំនឹកនាងជាខ្លាំង ខ្លាំងទាល់តែខ្ញុំសំរេចចិត្តថា ខ្ញុំត្រូវតែធ្វើ



ដំណើរទៅស្រុកពោធិហ្មស្ត្រីថ្ងៃស្អែកនេះ ទោះបីជួបនាងក៏ដោយពុំជួបក៏ដោយ ឲ្យតែបានទៅដល់ទីកន្លែងដែលនាងធ្លាប់នៅនោះ ខ្ញុំនឹងបានធូរស្បើយរំហើយទុក្ខខ្លះៗ ជាពុំខាន ។

យប់នេះ ខ្ញុំបានចូលទៅជំរាបលាឪពុកម្ដាយខ្ញុំ ។ ដំបូងលោកពុំចង់ឲ្យខ្ញុំទៅណាឆ្ងាយពីលោកឡើយ ។ ខ្ញុំព្យាយាមអធិប្បាយជំរាបលោកថា ពេលនេះ ខ្ញុំក៏នៅពុំទាន់ចេញមុខមាត់បាន បើទុកជានៅទីនេះក៏គ្មានប្រយោជន៍អ្វីដែរ ហើយសព្វថ្ងៃនេះ ខ្ញុំមានការធុញទ្រាន់នឹងជីវិតក្នុងទីក្រុងជាខ្លាំង ខ្ញុំមានបំណងចង់ចេញទៅសម្រាកកាយសម្រាកចិត្ត នៅឯស្រុកស្រែចំការ ហើយស្រុកស្រែចំការដែលខ្ញុំជ្រើសរើសនោះ គឺស្រុកពោធិហ្មស្ត្រី ព្រោះស្រុកនោះខ្ញុំមានមិត្តភក្តិរាប់អានស្គាល់គេច្រើនផង ។ កាលបើខ្ញុំពន្យល់ហេតុផលយ៉ាងនេះ លោកក៏ព្រមអនុញ្ញាតឲ្យខ្ញុំទៅ ។

— សុំកូនរក្សាខ្លួនប្រាណឲ្យល្អណាកូន! (ម្ដាយរបស់

ខ្ញុំបានផ្តាំ) ម៉ែសង្ឃឹមថា កូនអាចមកកម៉ែវិញ ឲ្យម៉ែបាន ជួបមុខកូនទៀតជាពុំខាន ។

– កូន! (ឪពុករបស់ខ្ញុំសួរ) កូនឯងទៅប៉ុន្មានថ្ងៃ ?

– ពុំកំណត់ទេប៉ា! បើទីនោះស្រួល ខ្ញុំក៏ចេះតែនៅឯណោះ ព្រោះពុំចង់ឲ្យអ្នកណាឃើញមុខមាត់ តែយូរៗ ខ្ញុំគង់នឹងមកលេងម្តង –

– កូន! (ម្តាយរបស់ខ្ញុំឆ្លើយឡើង) សុំកូនកុំទៅយូរពេកណា៎ ឆាប់មកវិញ ...

ព្រឹកស្អែកឡើង ខ្ញុំក៏សំពះលាឪពុកម្តាយធ្វើដំណើរទៅបាត់ដំបង តាមរថភ្លើង ដើម្បីទៅកាន់ស្រុកពោធិហ្នស្រ្តី ។

ខ្ញុំទ្រាំនៅភូមិ ពោធិហ្នស្រ្តី នេះ ទាំងទុក្ខក្រៀមក្រំ ព្រោះពុំបានជួបនឹងនាង យូរ៉េត របស់ខ្ញុំ ។

មីង ជែម នាងសាម៉ុន ជាម្ចាស់ផ្ទះដែលនាង យូរ៉េត



សំណាក់នៅ បាននិយាយប្រាប់ខ្ញុំពីរឿងនាង យូរ៉េត យ៉ាងល្អិតល្អន់ ... និយាយពីរឿងដែលនាងមានសេចក្តីទុក្ខសោក ... អស់សង្ឃឹម នៅពេលដែលនាងបានដឹងតាមសារពត៌មាន នឹងវិទ្យុថា ខ្ញុំត្រូវគេប្រហារជីវិតព្រោះរឿងក្បត់ជាតិ ... និយាយពីការដែលនាងបានចេញចាកស្រុកពោធិហ្នស្រ្តី នេះដោយឥតបានប្រាប់គេថា នាងទៅនៅទីណាពិតប្រាកដ តែនាងបានបញ្ចេញចេតនាយ៉ាងខ្លាំងថា នាងចង់ទៅប្រទេសសៀម ប្រសិនបើនាងអាចទៅបាន ព្រោះនាងមានបងប្អូនម្នាក់នៅក្រុងបាងកក ...

# ជំពូកទី ៣

## វគ្គទី ១៣

## តើឪពុកបំបែកកូនពីគូស្នេហាបានឬ ?

ខ្ញុំបានកំណត់ពេលទុកថា បីថ្ងៃទៀតនឹងត្រឡប់ទៅភ្នំពេញវិញ ...

ប៉ុន្តែនៅថ្ងៃទី ២ នៃការកំណត់នេះ ខ្ញុំបានទទួលដំណឹងថ្មីមួយតាមទូរលេខពីឪពុករបស់ខ្ញុំ ... ដំណឹងនេះជាដំណឹងកាចសាហាវ ជាដំណឹងដែលដូចជាមានអានុភាពអាចចូលទៅកាត់ផ្តាច់ទ្រូងនៃបេះដូងរបស់ខ្ញុំ ... គឺដំណឹងអំពីការអនិច្ចកម្មនៃម្តាយរបស់ខ្ញុំ ... ឪពុករបស់ខ្ញុំបានប្រាប់ថា ម្តាយរបស់ខ្ញុំបានស្លាប់តាំងពីម្សិលមិញដោយរោគដាច់សរសៃឈាម ...

សេចក្តីទុក្ខសោករបស់ខ្ញុំក្នុងពេលនេះ ដូចជាមានទំហំធំ



ហួសវិស័យនឹងពណ៌នាដូចម្តេចបាន ... ខ្ញុំត្រូវសម្ងំនៅសៀមស្ងាត់បណ្តោយពេលវេលាឲ្យកន្លងផុតទៅតាមអំពើចិត្តនៃអារម្មណ៍ដែលពោរពេញដោយសេចក្តីទុក្ខសោកនោះ ...

លុះដល់ថ្ងៃត្រូវត្រឡប់ទៅភ្នំពេញវិញ ខ្ញុំក៏ប្រែចិត្ត គិតថាប្រសិនបើម្តាយរបស់ខ្ញុំគ្រាន់តែមានជម្ងឺធ្ងន់ នៅពុំទាន់ស្លាប់ទេនោះ ខ្ញុំក៏គួរតែប្រញាប់ប្រញាល់ត្រឡប់ទៅឲ្យទាន់ដង្ហើម តែនេះលោកស្លាប់ផុតទៅហើយ បើទុកជាខ្ញុំត្រឡប់ទៅវិញក៏គ្មានប្រយោជន៍អ្វី ក្រៅពីការរឹងរិតតែនាំឲ្យមានទុក្ខសោកធ្ងន់ទៀតឡើយ ។ លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចចិត្តថា ត្រូវតែសម្ងំនៅទីនោះបន្តិចទៀតសិន ដើម្បីឲ្យបានធូរស្រាលនូវសេចក្តីទុក្ខក្រៀមក្រំ ។

ប្រាំថ្ងៃ ក្រោយពេលបានទទួលដំណឹងមរណភាពនៃម្តាយរបស់ខ្ញុំនៅភូមិពោធិហ្លស្ត្រី បានកន្លងផុតទៅជាប់ដោយសេចក្តីទុក្ខសោកក្រៀមក្រំសំកប់រូបខ្ញុំ ខ្ញុំក៏មានគំនិតថ្មីមួយ

ផុសឡើងថា កាលម្ដាយរបស់ខ្ញុំមានជីវិតរស់នៅឡើយ រឿងប្រពន្ធកូនរបស់ខ្ញុំនោះ គឺស្រេចនៅលើលោកជាអ្នកចាត់ចែង គឺថាបើលោកពេញចិត្តនារីណា ខ្ញុំត្រូវតែចូលចិត្តតាមខានពុំបាន ។ ការដែលធ្វើយ៉ាងនេះ ខ្ញុំក៏ឥតមានអាក់អន់ចិត្តអ្វីនឹងលោកដែរ ព្រោះម្ដាយខ្ញុំនៅកាន់ទម្លាប់បូរាណ ដែលពុំបានបើកសិទ្ធិឲ្យបុត្រជ្រើសគូតាមចិត្តរបស់ខ្លួនឡើយ ។ ឯឪពុករបស់ខ្ញុំវិញពុំជាការអ្វីទេ លោកមុខជាយល់ដល់ចិត្តថ្លើមរបស់ខ្ញុំខ្លះៗជាពុំខាន ព្រោះលោកក៏ជាប្រុសដូចខ្ញុំដែរ ហើយមានការសិក្សាចេះដឹងគួរសមផង ។ ខ្ញុំគិតថា បើទុកជាយ៉ាងណា ក៏ខ្ញុំអាចអង្វរករលោកបាន ។ លុះគិតដូច្នេះហើយ ខ្ញុំក៏សំរេចខ្លួនឯងថា នឹងធ្វើដំណើរទៅតាមនាង យូរ៉េត របស់ខ្ញុំ ។

ខ្ញុំបានសាកសួរមីង ឆែម និងនាង សាម៉ុន ពីអាសយដ្ឋានរបស់នាង យូរ៉េត នៅទីក្រុងបាងកក ។ គេឆ្លើយ



ថាគេក៏ពុំបានដឹងដែរ ដោយដឹងត្រឹមតែថា នាងមានឪពុកមាម្នាក់ធ្វើការនៅក្នុងក្រសួងការបរទេសនៃប្រទេសថៃ ។ គេបានបញ្ជាក់ថា ប្រសិនបើនាង យូរ៉េត ទៅបាងកកមែននោះ នាងមុខជាទៅនៅជាមួយនឹងឪពុកមាដែលឈ្មោះ ឌីរ៉ង នោះ ។

មួយសប្ដាហ៍ក្រោយមក ខ្ញុំក៏ប្រថុយធ្វើដំណើរទៅក្រុងបាងកកតែម្នាក់ឯង ដោយពុំបានប្រាប់ឲ្យអ្នកណាដឹងសោះឡើយ សូម្បីតែមីង ឆែម ជាម្ចាស់ផ្ទះនេះ ក៏ខ្ញុំពុំបានជំរាបឲ្យដឹងដែរ ។

លុះទៅដល់ក្រុងបាងកក ខ្ញុំក៏បានទៅសំណាក់នៅសណ្ឋាគារដ៏តូច ហើយស្នាក់នៅសួនលុំ, នៅជិតស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំក្រុងបាងកក ។ ខ្ញុំពុំបានបណ្ដោយពេលវេលាឲ្យកន្លងផុតទៅដោយឥតប្រយោជន៍ ក្នុងការស៊ើបសួររកនាង យូរ៉េត របស់ខ្ញុំឡើយ ។ បីថ្ងៃនៅក្រុងបាងកក ខ្ញុំបានទៅរកផ្ទះលោក ឌីរ៉ង ឃើញ ហើយខ្ញុំបានជួបនាង

យូរ៉េត របស់ខ្ញុំនៅទីនោះ ។

ខ្ញុំពុំអាចអធិប្បាយដល់ទឹកចិត្តរបស់ខ្ញុំនឹងនាង យូរ៉េត ក្នុងពេលនោះបានឡើយ ... ក្នុងពេលដែលគេប្រាប់នាងថា មានមនុស្សមករកនាងនោះ នាងក៏ដូចជាឆ្ងល់ តែលុះនាងចេញដើរមកជិតខ្ញុំ នាងក៏ឈរសំឡឹងមើលមុខខ្ញុំស្រឡាំងកាំង ដោយឥតមាននិយាយស្តីថាអ្វី ... បើតាមខ្ញុំស្មានថាដោយសារការត្រេកអរខ្លាំងពេក នាងពុំអាចហានិយាយស្តីអ្វីរួច ... ខ្ញុំក៏ចាប់ផ្តើមសួរនាងមុនថា :

- យូរ៉េត អូន ! អូនបានសុខសប្បាយជាទេ ?
- ចាស ! ពុំសូវជាសុខសប្បាយប៉ុន្មានទេ ...
- ម៉េចអញ្ចឹង ?
- ប៉ុន្មានថ្ងៃមកហើយ ខ្ញុំដូចជាបានធូរស្បើយសប្បាយរីករាយបន្តិចទៅហើយ តែលុះមកឃើញមុខបង ចិត្តក៏ដូចជាលែងសប្បាយរីករាយដូចថ្ងៃមុន ប្រែទៅជាក្រៀមក្រំទៅវិញ ។



- ម៉េចក៏ យូរ៉េត និយាយអញ្ចឹង ?
- ក៏ព្រោះខ្ញុំបានជួបមុខមនុស្សដែលខ្ញុំស្រឡាញ់ ដែលខ្ញុំពុំបានទឹកនាសោះថានឹងបានជួប - មនុស្សដែលខ្ញុំស្រឡាញ់នោះ បានធ្វើគុណប្រយោជន៍ដល់រូបខ្ញុំជាច្រើន ដែលខ្ញុំបានបង្កប់ទុកក្នុងចិត្តជានិច្ចថា ខ្ញុំពុំអាចបំភ្លេចគុណគេពោលបានក្នុងមួយជីវិតនេះ - ខ្ញុំបានលះបង់អ្វីគ្រប់យ៉ាង ដើម្បីជូជាគុណបំណាច់មនុស្សនោះ - ទីបំផុតខ្ញុំសុខចិត្តលះបង់សេចក្តីស្នេហាដ៏ធំរបស់ខ្ញុំចំពោះមនុស្សនោះ ដើម្បីអនាគតរបស់គេ- ហើយតមកខ្ញុំបានឮដំណឹងយ៉ាងក្រៀមក្រំថា មនុស្សដែលខ្ញុំស្រឡាញ់ស្មើដោយជីវិតនោះ ត្រូវស្លាប់បាត់បង់ជីវិតទៅហើយ ដែលជាការរឹតតែធ្វើឲ្យខ្ញុំមានជីវិតរស់នៅពោរពេញដោយការទុក្ខសោកនឹងអស់សង្ឃឹម ...

ខ្ញុំបានអធិប្បាយរឿងរ៉ាវទាំងអស់ប្រាប់នាង យូរ៉េត ហូតដល់រឿងមរណភាពនៃម្តាយរបស់ខ្ញុំ ... ខ្ញុំបានប្រាប់

នាងថា ខ្ញុំនៅមានសង្ឃឹមថា ឪពុករបស់ខ្ញុំមុខជាបណ្ដោយតាមចិត្តរបស់ខ្ញុំក្នុងរឿងនេះជាពុំខាន ... ទីបំផុត ខ្ញុំបានប្រាប់នាងថា :

– គ្មានអំណាចអ្វីក្នុងលោកនេះ ក្រៅពីសេចក្ដីស្លាប់ អាចមកពង្រាត់បម្រាសយើងទាំងពីរ ឲ្យព្រាត់ប្រាសនិរាសចាកចេញពីគ្នាបានឡើយ ...

នាង យូរ៉េត ក៏ពុំនិយាយស្ដីអ្វី ... នាងអន្ទងសម្រក់ទឹកភ្នែកនៅចំពោះមុខខ្ញុំ ...

តពីនោះមកប្រាំថ្ងៃ ខ្ញុំក៏លែងសំណាក់នៅលើសណ្ឋាគារ ស្ងួនល់ ។ ខ្ញុំបានទៅជួលផ្ទះនៅ ហើយបាននាំនាង យូរ៉េត ទៅនៅជាមួយ ។

ខ្ញុំបានផ្ញើសំបុត្រទៅជម្រាបឪពុករបស់ខ្ញុំនូវហេតុការណ៍ទាំងអស់ ។ ជាពិសេសខ្ញុំបានជំរាបអំពីរឿងនាង យូរ៉េត និងខ្លួនខ្ញុំយ៉ាងល្អិតល្អន់ ។ ខ្ញុំបានសុំអង្វរលោកឲ្យលោក



មេត្តាយល់ព្រមតាមខ្ញុំ គឺសុំឲ្យលោកព្រមទទួលយកនាង យូរ៉េត ធ្វើជាកូនប្រសា ដែលក្នុងពេលពុំយូរប៉ុន្មាន ខ្ញុំនឹងត្រូវនាំនាងត្រឡប់ទៅស្រុកខ្មែរវិញ ។

ចាប់តាំងពីពេលនោះមក ខ្ញុំក៏បានប្រកបការងារចិញ្ចឹមជីវិតគ្រប់បែបយ៉ាង ដែលខ្ញុំអាចធ្វើបាន ហើយយើងក៏មានជីវភាពយ៉ាងចង្អៀត ។

ប្រហែលជាបីខែក្រោយមក ខ្ញុំបានទទួលដំណឹងតាមសំបុត្រពីឪពុករបស់ខ្ញុំមួយច្បាប់ ។ ដំណឹងនេះជាដំណឹងអាក្រក់សំរាប់រូបខ្ញុំ ឬបើយ៉ាងនេះហោចណាស់ ក៏ជាដំណឹងដ៏អាក្រក់សំរាប់ឪពុកដែលផ្ញើមកកូនវិញ ព្រោះគាត់បានសរសេរផ្ញើមកទាំងសេចក្ដីទោមនស្សដ៏ខ្លាំងចំពោះរូបខ្ញុំ ដែលហ៊ានតាមស្ត្រីដល់ក្រុងបាំងកក ។ លោកបានបញ្ជាក់ត្រង់ចំណុចខាងចុងថា លោកនឹងពុំព្រមឲ្យខ្ញុំយកនាង យូរ៉េត ធ្វើជាប្រពន្ធជាដាច់ខាត ។ មិនតែប៉ុណ្ណោះ លោកបាន

និយាយយ៉ាងដាច់ខាតទៀតថា ឲ្យខ្ញុំត្រឡប់ទៅស្រុកវិញយ៉ាងដាច់ ហើយត្រឡប់ទៅតែម្នាក់ឯង ដើម្បីរៀបចំខ្លួនប្រាណរៀបមង្គលការតាមបណ្ដាំម្ដាយរបស់ខ្ញុំ ។ នាង យូរ៉ែត នោះត្រូវតែលែងលះគ្នាឲ្យជ្រះស្រឡះទៅ ។

បញ្ហានេះជាបញ្ហាដ៏សំខាន់សំរាប់រូបខ្ញុំ ជាបញ្ហាដែលខ្ញុំពុំហ៊ានប្រាប់ឲ្យនាង យូរ៉ែត ដឹងឡើយ ព្រោះកាលដើមខ្ញុំបានប្រាប់នាងថា សំរាប់ឪពុករបស់ខ្ញុំនោះពុំជាអ្វីប៉ុន្មានទេ បើអង្វរករលោកយូរៗទៅ លោកមុខជាយល់ព្រមតាមជាពុំខាន..., ហើយខ្ញុំបានតាំងបញ្ឈាក់ប្រាប់នាងថា នៅមានសង្ឃឹមនឹងអង្វរករឪពុករបស់ខ្ញុំបានទៀតផង – តែឥឡូវដល់រឿងក៏កែប្រែដូច្នេះ ខ្ញុំក៏ពុំហ៊ានប្រាប់នាងឲ្យដឹងឡើយ...

ពេលនេះ សំរាប់រូបខ្ញុំវិញ ខ្ញុំក៏ពុំអាចលះបង់នាងយូរ៉ែតចោល ហើយត្រឡប់ទៅស្រុកវិញតែម្នាក់ឯងបានឡើយ... សូម្បីតែត្រូវបែកគ្នាមួយពេលមួយគ្រាសិនក៏ដោយ ក៏ខ្ញុំដូច



ជាធ្វើពុំកើតដែរ... ការនេះប្រែសេចក្ដីថា ខ្ញុំពុំអាចត្រឡប់ទៅស្រុកវិញតែម្នាក់ឯងបានទេ ប្រសិនបើឪពុករបស់ខ្ញុំ ពុំយល់ព្រមតាមពាក្យអង្វររបស់ខ្ញុំ...

ខ្ញុំបានសរសេរសំបុត្រផ្ញើទៅជូនឪពុករបស់ខ្ញុំវិញ ដោយបាននិយាយពន្យល់ហេតុផលគ្រប់យ៉ាងជូនលោកស្ដាប់ ។ ខ្ញុំយល់ថា ការឆ្លើយឆ្លងគ្នាតាមផ្លូវសំបុត្ររវាងខ្ញុំនិងឪពុករបស់ខ្ញុំនោះត្រូវប្រើពេលយូរបន្តិច ។

យើងនៅរួមរស់ជាមួយគ្នាដោយសេចក្ដីសុខ នៅក្នុងគេហដ្ឋានមួយដ៏តូច ដែលតាំងនៅលើផ្លូវដ៏ធំគួរសម តែដាច់ស្រយាលពីគេនៅជាយក្រុង ។ យើងមានស្ត្រីបំរើម្នាក់ដែលល្មមឲ្យសេចក្ដីសុខ តែសេចក្ដីសុខនេះជាសេចក្ដីសុខដែលខ្ញុំពុំអាចដឹងថា នឹងអាចឋិតថេរបើកាលយើនយូរទៅបានអស់ពេលត្រឹមណា...

ឪពុករបស់ខ្ញុំ ពុំបានសរសេរសំបុត្រឆ្លើយមកខ្ញុំវិញភ្លាមទេ..

ការដែលលោកពុំសរសេរឆ្លើយតាមដូច្នេះ គឺប្រហែលជាលោកខឹងសម្បានឹងខ្ញុំខ្លាំងណាស់ ហើយចង់កាត់កាល់ខ្ញុំចោលក៏ពុំដឹង តែសំរាប់រូបខ្ញុំវិញ ខ្ញុំគ្មានខឹងសម្បាអ្វីនឹងលោកឡើយ ... ខ្ញុំគិតថាប្រសិនបើលោកខឹងនឹងខ្ញុំនោះ ក៏គួរនឹងហេតុមែន ព្រោះបើទុកមាថារូបខ្ញុំជាឪពុកហើយមានកូនដែលខ្លួនខ្ញុំបានថ្នាក់ថ្នមបញ្ចឹមបីបាច់ថែរក្សាតាំងពីតូចរហូតដល់ធំ ដោយបានទំនុកបំរុងឲ្យរៀនសូត្រទាល់តែបានចេះដឹងប៉ុណ្ណោះ ហើយទីបំផុតកូននោះពុំស្តាប់បង្គាប់ខ្ញុំជាឪពុកនោះ ក៏គួរឲ្យខ្ញុំខឹងនឹងដែរ ... តែយ៉ាងណាក៏ដោយចុះ ខ្ញុំក៏នៅតែមានសង្ឃឹមថា ឪពុករបស់ខ្ញុំក៏មុខជាយល់ព្រមតាមពាក្យអង្វររបស់ខ្ញុំជាពុំខាន ...

ក្រោយពីពេលនោះបន្តិចមកនាង យូរ៉េត បានប្រាប់ខ្ញុំថា នាងមានផ្ទៃពោះជាងពីរខែមកហើយ ។ ដំណឹងនេះបានធ្វើឲ្យខ្ញុំរឹងរឹតតែធូរចិត្តឡើងទៀត ។



ពិតណាស់ហើយ កូនដែលនឹងត្រូវកើតមកនោះ ក៏មុខជានឹងក្លាយទៅជាចំណងសំរាប់ចងកខ្ញុំ ឲ្យរឹងរឹតតែតឹងឡើងទៀត លើពាក្យប្តេជ្ញាដែលយើងបានសន្យាចំពោះមុខគ្នាថា នឹងពុំព្រមឲ្យអំណាចអ្វីមួយក្នុងលោកមកពង្រាត់បំរាស់យើងបានក្រៅពីសេចក្តីស្លាប់នោះឡើយ ... ប៉ុន្តែជួនកាលកូនដែលនឹងត្រូវកើតមកនេះ ក៏អាចជាប្រយោជន៍ដល់យើងខ្លះដែរ ព្រោះប្រសិនបើឪពុករបស់ខ្ញុំបានជ្រាបថា ឥឡូវនេះនាង យូរ៉េត មានផ្ទៃពោះហើយនោះ លោកមុខជាមានចិត្តទោរទន់អាណិតអាសូរខ្លះៗជាពុំខាន ... ខ្ញុំបានសរសេរសំបុត្រទៅជំរាបលោកថា ពេលនេះលោកឪពុកកំពុងតែក្លាយខ្លួនទៅជាជីតារបស់ទារកម្នាក់ដែលកើតពីនាង យូរ៉េត ព្រោះសព្វថ្ងៃនេះ នាងកំពុងតែមានផ្ទៃពោះ ... ខ្ញុំបានអង្វរលោកថា ប្រសិនបើលោកឪពុកពុំអាណិតអាសូរនាង យូរ៉េត ទេនោះ ក៏សូមឲ្យអាណិតតែទារកដែលកំពុងតែប្រុងប្រៀប

ខ្លួនចេញមកបើកភ្នែកមើលពិភពលោក ហើយដែលក៏ជាសាច់ឈាមរបស់លោកឪពុកដោយពិតៗ នោះផងទៅចុះ...

ក្នុងពេលនោះ ខ្ញុំថ្នាក់ថ្នមនាង យូរ៉េត ដូចកែវភ្នែក ឬដូចកែវនៃជីវិត... ខ្ញុំជឿជាក់ថាកូនដែលនឹងត្រូវកើតមកនេះ មុខតែពុំមែនជាកូនដែលមានសភាពទន់ខ្សោយ ឬល្ងង់ខ្លៅឡើយ.... ឯនាង យូរ៉េត វិញ ក៏បានប្រព្រឹត្តខ្លួនជាប្រពន្ធដ៏ល្អជាទីបំផុត... ខ្ញុំពុំដែលមានប្រពន្ធ ខ្ញុំពុំអាចលើកយកនាងទៅប្រៀបធៀបនឹងអ្នកណាឲ្យសមឡើយ តែប្រសិនបើពិនិត្យគិតថា នៅមានអ្វីខ្វះទៀតដែលខ្ញុំត្រូវការពីនាង យូរ៉េត ហើយនៅពុំទាន់បាននោះ ខ្ញុំក៏ដូចជានឹករកពុំឃើញ ព្រោះសព្វថ្ងៃ ខ្ញុំមានអ្វីគ្រប់បែបគ្រប់យ៉ាង ត្រូវតាមសេចក្តីប្រាថ្នាទាំងអស់... រូបខ្ញុំក្នុងពេលនេះដូចជាត្រូវតាមពុទ្ធដីការបស់ព្រះសង្ឃដែលតែងប្រទានពរថា " សូមឲ្យសេចក្តីប្រាថ្នាទាំងឡាយ ទាំងពួងបានសំរេចដល់អ្នក " ។



មានពេលច្រើនដងណាស់ ដែលនាង យូរ៉េត សួរខ្ញុំ កាលណាយើងនឹងត្រឡប់ទៅស្រុកវិញ? សំនួរនេះបានធ្វើឲ្យខ្ញុំពិបាកចិត្តជាខ្លាំង ព្រោះខ្ញុំពុំដឹងជាឆ្លើយប្រាប់នាងវិញជាដូចម្តេច... ខ្ញុំពុំអាចឆ្លើយប្រាប់នាងវិញថា ឪពុករបស់ខ្ញុំពុំព្រមទទួលយកនាងធ្វើជាកូនប្រសា ឬក៏ខ្ញុំបានទទួលសំបុត្ររបស់ឪពុកខ្ញុំ ដែលមានពាក្យបណ្តាំថា ឲ្យខ្ញុំត្រឡប់ទៅស្រុកវិញតែម្នាក់ឯង ឬក៏អ្វីៗដែលពុំមែនជាដំណឹងល្អសម្រាប់រូបនាងនោះបានឡើយ ... ខ្ញុំគិតថា ខណៈនេះនាងកំពុងតែមានផ្ទៃពោះ – កូនដែលឋិតនៅក្នុងពោះរបស់នាងនោះ ជាជីវិតទីពីររបស់ខ្ញុំ... កូននេះនឹងអាក្រក់ឬល្អក៏ស្រេចនៅលើសភាពដួងចិត្តរបស់ម្តាយ ក្នុងពេលមានទម្ងន់ ព្រោះតែរឿងនេះ វាមានការទាក់ទងគ្នាសំខាន់ណាស់ ..

ប៉ុន្តែកាលបើនាងចេះតែសួររឿយៗ ខ្ញុំក៏ត្រូវរកពាក្យដោះសារផ្សេងៗដែរ... ខ្ញុំបានប្រាប់នាងថា ខ្ញុំដូចជាលែង

បងត្រឡប់ទៅស្រុកវិញហើយ ព្រោះការរកស៊ីចិញ្ចឹមជីវិតសព្វថ្ងៃនេះ គឺដូចជាបានចំរើនគួរសមដែរ...

– បើអញ្ចឹង (នាង យូរ៉េត និយាយ) គឺប្រែសេចក្តីថារូបអូនជាអ្នកទម្លាយនូវគោលគតរបស់បង ...

– សុំអូនកុំនិយាយអញ្ចឹង យើងអាចគិតថា នេះជាការប្រែប្រួលនៃជីវិតទៅចុះ ...

បួនខែបានកន្លងផុតទៅទៀត ប្រសិនបើគិតពីពេលដែលខ្ញុំបានសរសេរសំបុត្រទៅជំរាបឪពុករបស់ខ្ញុំថា នាង យូរ៉េត មានផ្ទៃពោះនោះ ខ្ញុំក៏បានទទួលនូវសំបុត្ររបស់ឪពុកខ្ញុំមួយច្បាប់ទៀត ។ សំបុត្រនេះក៏ពុំបានធ្វើឲ្យសភាពការណ៍ផ្លាស់ប្តូរប្រែប្រួលទៅជាយ៉ាងណាឡើយ ព្រោះឪពុករបស់ខ្ញុំនៅតែប្រកាន់យ៉ាងមុឺងម៉ាត់ថា លោកនៅតែពុំព្រមទទួលយកនាង យូរ៉េត ធ្វើជាកូនប្រសាដដែល សូម្បីនាងមានកូនប៉ុន្មាននាក់ហើយក៏ដោយ ។ ក្រៅពីនោះ លោកនៅតែប្រាថ្នាឲ្យខ្ញុំត្រឡប់



ទៅស្រុកវិញ ដើម្បីរៀបការជាមួយនារីម្នាក់ដែលលោកបានដណ្តឹងទុកឲ្យ តាមបណ្តាំម្តាយរបស់ខ្ញុំ ហើយលោកឲ្យត្រឡប់ទៅវិញតែម្នាក់ឯង ពុំព្រមឲ្យយកនាង យូរ៉េត ឬ កូនទៅជាមួយផងឡើយ ។

តាមពិត ឪពុករបស់ខ្ញុំក៏ពុំអាចរាំង ឬ ហាមឃាត់ពុំឲ្យយកនាង យូរ៉េត ទៅជាមួយផងនោះបានឡើយ ខ្ញុំអាចនាំយកនារីទៅលាក់ទុកនៅកន្លែងណាមួយក៏បាន ដោយពុំជូនលោកជ្រាប តែប្រសិនបើខ្ញុំធ្វើដូច្នេះទៅ ផលអាក្រក់នឹងកើតឡើងដល់នាងយ៉ាងណា ! ខ្ញុំគិតថា ថ្ងៃណាមួយនាងមុខជាដឹងថា ឪពុកក្មេកនាងពុំព្រមទទួលយកនាងឲ្យចូលជាសមាជិកគ្រួសារ ហើយពេលនោះនាងមុខជាមានសេចក្តីទុកទោមនស្សយ៉ាងខ្លាំង ។ ពិសេសជាងនោះទៅទៀត ប្រសិនបើខ្ញុំត្រូវរៀបការជាមួយនឹងនារីណាម្នាក់ទៀតនោះ ផលអាក្រក់យ៉ាងខ្លាំងគឺមុខជាកើតឡើងដល់នាង យូរ៉េត យ៉ាងពិត

ប្រាកដ គិតដូច្នេះហើយ ខ្ញុំក៏បានសរសេរសំបុត្រផ្ដាំសារផ្ញើទៅជូនលោកឪពុកខ្ញុំទៀត ក្នុងការដែលខ្ញុំនៅពុំទាន់បានត្រឡប់ទៅស្រុកវិញនោះថា ដោយសារតែពេលនេះ នាង យូរ៉េត កំពុងតែមានផ្ទៃពោះនោះ បានជាខ្ញុំពុំអាចលះបង់នាងចោល ។ ខ្ញុំបានអង្វរករលោកថា សូមឲ្យខ្ញុំបាននៅជាមួយនាង ទាល់តែដល់ពេលដែលនាងបានសម្រាលកូនរួចសិន ឬក៏ទុកពេលឲ្យខ្ញុំចាត់ការរៀបចំឲ្យនាង យូរ៉េត មានមុខរបររកស៊ីចិញ្ចឹមជីវិតឲ្យបានស្រួលបួលសមគួរដល់អត្តភាពសិននោះ ខ្ញុំនឹងត្រឡប់ទៅស្រុកវិញភ្លាម ។

ចាប់តាំងពីពេលនោះមក ខ្ញុំក៏លែងបានទទួលសំបុត្រ ឬដំណឹងអ្វីពីឪពុករបស់ខ្ញុំទៀតសោះ ។

ឥឡូវនាង យូរ៉េត បានសំរាលកូនហើយៗ ជាកូនប្រុសផង ។ ខ្ញុំពុំអាចអធិប្បាយអំពីមនោសញ្ចេតនារបស់ខ្ញុំឲ្យច្បាស់លាស់ជាលាយលក្ខអក្សរបានឡើយ ... សភាពនៃ



ទឹកចិត្តដែលដឹងខ្លួនថាជាឪពុក ឪពុកដែលមានកូនកើតមកដោយឈាមមួយដុំរបស់ខ្លួននោះ បានធ្វើឲ្យខ្ញុំមានសេចក្ដីត្រេកអររីករាយយ៉ាងលើសលប់រកអ្វីប្រៀបគ្មាន ... ជាសេចក្ដីស្នេហាដែលខ្ញុំពុំធ្លាប់មានពុំធ្លាប់ដឹងមកពីពេលមុនឡើយ ... ការបានមាសប្រាក់ ការប្រឡងជាប់ជាដើមទាំងនេះ ក៏បានធ្វើឲ្យខ្ញុំត្រេកអររីករាយសប្បាយចិត្តជាខ្លាំង ឬក៏ការបានជួបនិងនាង យូរ៉េត វិញនោះ ក៏បានធ្វើឲ្យខ្ញុំត្រេកអររីករាយសប្បាយចិត្តខ្លាំងណាស់ដែរ តែការត្រេកអរឬរីករាយសប្បាយចិត្តទាំងនោះ ក៏នៅតែពុំទាន់ដែលជ្រួតជ្រាបដូចការត្រេកអរនឹងរីករាយសប្បាយចិត្ត ក្នុងពេលដែលខ្ញុំបានកូនប្រុសមួយនេះដែរ សូម្បីរូបខ្ញុំជាអ្នកសរសេររឿងក៏ខ្ញុំពុំអាចបរិយាយឲ្យបានច្បាស់លាស់ ថាការត្រេកអរនឹងសេចក្ដីរីករាយសប្បាយចិត្តនោះ មានសភាពយ៉ាងណាឡើយ ...

ក្នុងពេលជាមួយគ្នានេះ ខ្ញុំបាននឹកទៅដល់ឪពុករបស់ខ្ញុំ

ជាលោកប្រហែលជាត្រេកអររីករាយសប្បាយស្រឡាញ់ខ្ញុំ ដូចខ្ញុំស្រឡាញ់កូនខ្ញុំដែរនៅពេលដែលខ្ញុំកើត ... បើដូច្នោះ ជាការសមគួរ ឬ ដែលខ្ញុំនឹងទទឹងនឹងលោក ជំទាស់នឹងលោក ក្នុងការដែលលោកបានសំដែងនូវសេចក្តីប្រាថ្នា យ៉ាងខ្លាំងក្លា ថា ឲ្យខ្ញុំបោះបង់ចោលនាង យូរ៉េត បោះបង់ចោលកូន ហើយត្រឡប់ទៅស្រុកវិញតែម្នាក់ឯង ? ... ឧបមាថា កូនរបស់ខ្ញុំដែលទើបនឹងកើតនេះ កាលបើវាធំឡើងវានឹងទទឹងជំទាស់នឹងបំណងល្អរបស់ខ្ញុំ វាហ៊ានទៅយកប្រពន្ធតាមទំនើងវាវិញនោះ តើខ្ញុំនឹងធ្វើយ៉ាងណា ? ...

ខ្ញុំពិបាកចិត្តជាខ្លាំង ... ខ្ញុំគិតថា រូបខ្ញុំហាក់ដូចជាត្រូវបិតនៅក្នុងចន្លោះថ្មដ៏ធំពីរដុំ ដែលកំពុងតែរមៀលទិតចូលជិតគ្នាមកសង្កត់ខ្ញុំ... ម្ខាងឪពុក ម្ខាងទៀតកូន! ... ខ្ញុំពុំដឹងជាគេចទៅខាងណាឡើយ ... ក្នុងមួយជីវិតរបស់ខ្ញុំនេះ ខ្ញុំពុំដែលមានពេលណាពាល់ក្រោធដូចជាពេលនេះសោះឡើយ ...



ខ្ញុំបានសរសេរសំបុត្រជំរាបឪពុករបស់ខ្ញុំមួយច្បាប់ទៀតថា ឥឡូវនេះ នាង យូរ៉េត បានសំរាលកូនហើយ ។ កូននេះជាប្រុសទៀតផង ។ ខ្ញុំបានជំរាបលោកថា ខ្ញុំពុំអាចបាច់អធិប្បាយដល់មនោសញ្ចេតនារបស់ខ្ញុំថា យ៉ាងណាឡើយ ព្រោះខ្ញុំជឿជាក់ថា នៅពេលខ្ញុំកើតនោះ លោកឪពុកក៏ត្រេកអររីករាយសប្បាយចិត្ត ហើយស្រឡាញ់កូនរកអ្វីប្រៀបស្មើពុំបានដែរ ហើយប្រសិនបើពេលនោះមានអំណាចអ្វីទៅពង្រាត់បម្រាស់លោកឪពុកពីកូនឲ្យព្រាត់ប្រាស់ចែកខ្ញែកចេញពីគ្នានោះ លោកឪពុកក៏មុខជាមានទុក្ខទោមនស្សជាខ្លាំងដែរ ។ ខ្ញុំជឿជាក់ថា លោកឪពុកមុខជាហ៊ានប្រថុយស្លាប់ ដោយពុំព្រមព្រាត់ពីកូនឡើយ ឯឋានៈរបស់ខ្ញុំក្នុងពេលនេះ ក៏ដូចគ្នានឹងលោកឪពុកដែរ គឺខ្ញុំពុំអាចបែកចេញពីកូនខ្ញុំបានទេ សូមខ្ញុំបានសន្យានឹងលោកឪពុកថា កាលបើនាងយូរ៉េតសំរាលកូនរួចរាល់ហើយនោះ ខ្ញុំក៏នឹងបោះបង់នាងចោល តែឥឡូវនេះ

ខ្ញុំនៅពុំទាន់ដាច់ចិត្តបោះបង់នាងចោលបានឡើយ ព្រោះពីមុនខ្ញុំមានត្រឹមតែចំណងដៃ តែឥឡូវខ្ញុំមានចំណងកបន្ថែមមកមួយជាន់ទៀត ។ ដោយសារចំណងទាំងពីរនេះតឹងណែនជាប់ពេក ខ្ញុំក៏ពុំដឹងជានឹងស្រាយដូចម្ដេចបាន ដើម្បីឲ្យបានវិលត្រឡប់ទៅស្រុកវិញ ។

រឿងរ៉ាវទាំងអស់នេះ បានធ្វើឲ្យខ្ញុំពិបាកចិត្តជាខ្លាំង ព្រោះខ្ញុំត្រូវគិតតែម្នាក់ឯង ត្រូវសំរេចចិត្តតែម្នាក់ឯង ដោយខ្ញុំពុំអាចនិយាយប្រាប់ឲ្យនាង យូរ៉េត ដឹងបានឡើយ ព្រោះនាងទើបនឹងសំរាលកូនថ្មីៗ សរសៃនៅខ្ចី នាងនៅត្រូវការក្រឡាខ្លួនក្នុងដំណេកនៅឡើយ ម្ល៉ោះហើយខ្ញុំត្រូវតែប្រយ័ត្នប្រយែងជាទីបំផុត ដើម្បីកុំឲ្យមានរឿងរ៉ាវអ្វីពុំល្អប៉ះទង្គិចដល់ទឹកចិត្តនាងជាដាច់ខាត ។

ខ្ញុំស្រឡាញ់កូនប្រុសរបស់ខ្ញុំយ៉ាងពេញចិត្តជាខ្លាំង ។ វាជាក្មេងស្អាតបាតពុំដូចខ្ញុំទេ តែវាដូចម្ដាយរបស់វា ។



កាលបើថ្ងៃនឹងយប់ចេះតែកន្លងទៅ វាក៏ចេះតែចំរើនធំឡើងគ្រប់ៗខណៈដែរ ។ ខ្ញុំបានដាក់ឈ្មោះវាថា យូកាំ ដោយយកឈ្មោះម្ដាយនឹងឪពុកមកផ្សំគ្នា ព្រោះវាជាដុំឈាម ជាដួងកែវជីវិតនិងជាដួងចិត្តរបស់យើងទាំងពីរនាក់ ។

ដោយសារការនឹកដល់សភាពពុំទៀងទាត់នៃសង្គ្រាម និងដោយសារការយល់ព្រមពីនាង យូរ៉េត ផងនោះ ខ្ញុំក៏បានទៅធានាជីវិតរបស់ខ្ញុំទុកជាប្រាក់ចំនួន បីសែនបាត (ប្រហែលជាប្រាំសែនរៀលនៃប្រាក់ខ្មែរ) ។ កុងការធានានេះ មានកិច្ចសន្យាថា ប្រសិនបើខ្ញុំស្លាប់ដោយគ្រោះថ្នាក់ ក្រុមហ៊ុនដែលទទួលធានារ៉ាប់រងនឹងត្រូវសងប្រាក់បីសែនបាតនេះដល់នាង យូរ៉េត ឬដល់ យូកាំ ជាកូនរបស់ខ្ញុំ ។

ប្រាំបីខែបានកន្លងផុតទៅ យូកាំ កូនប្រុសរបស់ខ្ញុំ ក៏មានអាយុប្រាំបីខែដែរ ។ ស្ថានការណ៍ក៏គ្មានអ្វីផ្លាស់ប្ដូរប្រែប្រួលដែរ ។ ជីវិតក្នុងគ្រួសាររបស់យើងក៏បានប្រព្រឹត្តទៅ

ដូចជាធម្មតា ។ ដូចដែលយើងនិយាយថា ល្មមប្រព្រឹត្តទៅបាន ព្រោះមុខរបររកស៊ីចិញ្ចឹមជីវិតរបស់យើង ក៏បានចំរើនគួរសមដែរ រហូតដល់មានប្រាក់កាសយកទៅធានាជីវិត ។

នាង យ៉ូរ៉េត បានធ្វើខ្លួនជាប្រពន្ធដ៏ល្អជាទីស្រឡាញ់ពេញចិត្តរបស់ខ្ញុំរហូតមក ។ យើងពុំដែលទាស់ទែងខ្វែងគំនិតគ្នា ឬ ឈ្លោះប្រកែកគ្នាសោះឡើយ ។ យើងតែងស្រុះស្រួលជាមួយគ្នាជានិច្ច ហាក់ដូចជា បេះដូងពីរត្រូវយកមកផ្គុំគ្នានៅក្នុងដើមទ្រូងតែមួយ ។

តាំងពីនោះមក ខ្ញុំបានទិញរថយន្តមួយ ។ ការទិញរថយន្តនេះពុំមែនដើម្បីហ៊ឺហាទេ តែដើម្បីទុកសំរាប់ប្រើការចាំបាច់ ព្រោះខ្ញុំនៅជាយក្រុង ប្រសិនបើប្រពន្ធកូនឈឺថ្កាត់ ខ្ញុំអាចទៅតាមគ្រូពេទ្យបានដាប់រហ័ស ។ រថយន្តដែលខ្ញុំទិញនេះ ជារថយន្តតូចជំនំ ដែលមានតម្លៃយ៉ាងថោកគួរសម ។

វេលានេះ ខ្ញុំពុំដែលបានទទួលសំបុត្រ ឬ ដំណឹងអ្វីពី



ឪពុករបស់ខ្ញុំទេ ។ ខ្ញុំចេះតែនឹកព្រួយថា ក្រែងលោលោកមានជម្ងឺដំកាត់ ឬ អន្តរាយអ្វីបានជាបាត់ដំណឹងយ៉ាងនេះ ។

ខ្ញុំគិតម្យ៉ាងទៀតថា បើពុំដូច្នោះទេ ក៏ប្រហែលជាលោកកាត់កាល់ខ្ញុំចោល លែងនឹកនាខ្ញុំថាជាកូនទៀត ព្រោះឪពុករបស់ខ្ញុំពុំមែនមានកូនតែរូបខ្ញុំម្នាក់ឯងទេ នៅមានបងប្រុសរបស់ខ្ញុំម្នាក់ និងប្អូនស្រី-ប្រុសរបស់ខ្ញុំពីរនាក់ទៀត ។

វគ្គទី ១៤

# កិច្ចការពិសេស

ខ្ញុំចេះតែនៅក្រុងកន្លែងដើមនោះរហូតមក ព្រោះខ្ញុំគិតថា ដូចជាគ្មានហេតុការណ៍អ្វីដែលនឹងត្រូវផ្លាស់ប្តូរទីកន្លែងឡើយ ។

ថ្ងៃមួយ ខ្ញុំបានទទួលសំបុត្រមួយច្បាប់ ពីអ្នកបំរើសណ្ឋាគារ រតនៈកោស៊ិន នៅក្រុងបាងកក ។ នៅពេលដែលខ្ញុំបានសេចក្តីនៃសំបុត្រនោះ ខ្លួនរបស់ខ្ញុំត្រជាក់ស្រឹប – ដៃទាំងពីរញាប់ញ័រ ។

ឪពុករបស់ខ្ញុំ បានអញ្ជើញមកដល់ក្រុងបាងកកហើយ លោកបានសំណាក់នៅសណ្ឋាគារនោះ ក្នុងសំបុត្រលោកបានប្រាប់ឲ្យខ្ញុំចូលទៅជួបនឹងលោកជាប្រញាប់ ។

ពេលនោះជាពេលយប់ ខានយូរើត កំពុងតែប្រឡែង លេងជាមួយកូនទៅក្នុងបន្ទប់ដេក ។ ខ្ញុំបានប្រាប់នាងថា ខ្ញុំត្រូវទៅទីក្រុងបង្កក ព្រោះមានធុរៈសំខាន់ផ្ទាល់ខ្លួន ។ នាងបានផ្តាំខ្ញុំថា បើហាងលក់ដូរអីក៏នៅពុំទាន់បិទទ្វារទេ សូមទិញរបស់សំរាប់ក្មេងលេងយកមកផ្ញើកូនផង ។ ខ្ញុំនឹកតែក្នុងចិត្តថា ការនេះស្រួលដែរ ព្រឹកស្អែកខ្ញុំនឹងនាំកូនយកទៅបង្ហាញជីតា ។ ខ្ញុំគិតទៀតថា បើទុកជាជីតាមានចិត្តរឹងយ៉ាងណា ក៏គង់តែអាណិតអាសូរចៅខ្លះៗជាពុំខាន ។ កាលបើជីតាបានជួបមុខចៅក្នុងពេលដែលចៅចេះសើចចេះអរយ៉ាងនេះ ក៏មុខជាស្រឡាញ់ហើយចងដៃរបស់ខ្លួនមួយដ៏មានតម្លៃឲ្យចៅពុំលែង ។

ខ្ញុំពុំបាននឹកនាថា ឪពុករបស់ខ្ញុំមកតាមខ្ញុំដល់ក្រុងបាងកកដូច្នេះសោះ ។ ខ្ញុំក៏ដូចជានៅពុំទាន់ជឿថាឪពុករបស់ខ្ញុំមកតាមខ្ញុំពិតប្រាកដនៅឡើយទេ ប៉ុន្តែដើម្បីបញ្ជាក់ឲ្យដឹងពិតប្រាកដ ខ្ញុំបានទៅសុំមើលបញ្ជីនៃអ្នកសំណាក់សណ្ឋាគារ

មើល ៗ ខ្ញុំឃើញមានឈ្មោះឪពុករបស់ខ្ញុំមែន ៗ លោក ពុំមែនអញ្ជើញមកម្នាក់ឯងទេ នាំទាំងបងប្រុសរបស់ខ្ញុំមក ជាមួយផង ៗ

ការម្យ៉ាងដែលធ្វើឲ្យខ្ញុំចំលែកក្នុងចិត្តនោះ គឺក្នុងបញ្ជីនៃ អ្នកសំណាក់នោះ ឪពុកខ្ញុំនិងបងប្រុសខ្ញុំ បានចូលមកតាំង ពីប្រាំថ្ងៃមកហើយ ពុំមែនទើបមកដល់ទេ ៗ ខ្ញុំមានសេចក្ដី សង្ស័យជាខ្លាំង ព្រោះថា លោកត្រូវប្រើពេលវេលាស៊ើបសួរ រកខ្ញុំនោះ ក៏ដូចជាពុំមែនដែរ ព្រោះខ្ញុំបានដាក់ប្រកាសយ៉ាង ដល់លោកតាមផ្លូវលិខិតយ៉ាងច្បាស់លាស់ណាស់ ៗ លោក ធ្លាប់បានការខ្លួនសំបុត្រផ្ញើមកខ្ញុំយ៉ាងត្រឹមត្រូវ ចុះហេតុអ្វីក៏ បានជាលោកទើបនឹងប្រើគេយកសំបុត្រទៅឲ្យខ្ញុំ ? រឿងនេះ ក៏ដូចជារឿងដែលមានអាថ៌កំបាំងបិទមុខ គួរឲ្យពិចារណានឹង ថាពុំមែនឪពុកខ្ញុំក៏ថាពុំបាន ព្រោះក្នុងបណ្ណចុះឈ្មោះសំណាក់ នៅសណ្ឋាគារ ខ្ញុំស្គាល់ច្បាស់ថាហត្ថលេខារបស់លោក



ប្រាកដណាស់ ហើយហត្ថលេខាមួយទៀត ក៏ពិតជា ហត្ថលេខារបស់បងប្រុសខ្ញុំដែរ ៗ

ខ្ញុំមើលលេខបន្ទប់ហើយក៏ឡើងទៅរកលោក ៗ ខ្ញុំបាន ជួបនឹងឪពុករបស់ខ្ញុំ និងបងប្រុសរបស់ខ្ញុំមែន ៗ ខ្ញុំបានធ្វើ គារវកិច្ចចំពោះលោក ហើយក៏ស្ទុះទៅឱបបងប្រុសរបស់ខ្ញុំ ៗ បងប្រុសរបស់ខ្ញុំបានស្ទាបអង្អែលខ្នងខ្ញុំយ៉ាងថ្នាក់ថ្នមជាទីបំផុត ខ្ញុំបានអង្គុយចុះទៅលើកៅអីមួយ ហើយក៏ចាប់ផ្ដើមសួរឪពុក ខ្ញុំថា ៖

— ប៉ា ! ប៉ាមកសំណាក់នៅហូតែលនេះប្រាំថ្ងៃហើយឬ?

— ម៉េចក៏ឯងដឹង ?

— ខ្ញុំបានបើកបញ្ជីហូតែលមើលនៅខាងក្រោមអម្បាញ់ មិញហ្នឹងឯង

— ហ្នឹងហើយ ! ប៉ាមកសំណាក់នៅកន្លែងនេះប្រាំថ្ងៃ ហើយ

- ចុះម៉េចក៏ប៉ា ទើបតែឲ្យដំណឹងទៅខ្ញុំបាទក្នុងថ្ងៃនេះ អញ្ចឹង ?

- ព្រោះប៉ាដឹងថា កូនឯងពុំចង់ជួបនឹងប៉ា ប៉ាចេះតែទៅ ស្ទាក់ស្ទើររកចិត្ត ទីបំផុតក៏ដាច់ចិត្តឲ្យគេទៅតាមកូនឯងមក

- ម៉េចក៏ប៉ាប្រាប់ថា ខ្ញុំបាទពុំចង់ជួបប៉ា ?

- ចុះបើកូនឯងចង់ជួបនឹងប៉ាមែន ម៉េចក៏ពុំត្រឡប់ទៅ ស្រុកវិញ ?

- ខ្ញុំបាទ ចង់ត្រឡប់ទៅស្រុកវិញណាស់ ! ខ្ញុំបាទ នឹង ត្រឡប់ទៅវិញភ្លាម បើប៉ាមេត្តាអនុញ្ញាតឲ្យខ្ញុំបាទ នាំយក ប្រពន្ធកូនទៅជាមួយផង

- ចុះបើប៉ាពុំព្រមអនុញ្ញាត កូនឯងពុំព្រមត្រឡប់ទៅ វិញដែរ - អញ្ចឹងឬ ?

- ប៉ា ? រឿងនេះខ្ញុំបាទ ក៏ពុំដឹងជាធ្វើយ៉ាងម៉េចទេ ព្រោះអ៊ី យូរ៉េត ក៏បានជាជ្រុលខ្លួនជាប្រពន្ធខ្ញុំបាទ ហួសទៅ



ហើយ ។ ឥឡូវជ្រុលដល់ទៅមានកូនទៀតផង ។

- បើអញ្ចឹង កូនឯងស្រឡាញ់មី យូរ៉េត ជាងស្រឡាញ់ឪពុកឯង មែនទេ ?

- ខ្ញុំបាទ នឹងទៅនាំយកប្រពន្ធខ្ញុំបាទ ឲ្យមកជំរាបសួរ ប៉ា . . .

- កុំ ! កុំ ! មិនបានទេ - ប៉ាមិនត្រូវការជួបនឹងវាទេ

- ប៉ា (ខ្ញុំនិយាយបន្ត) ស្អែកខ្ញុំបាទ នឹងនាំកូន ខ្ញុំបាទ ឲ្យមកជំរាបសួរជីតាវ . . .

- ទេ ! ទេ ! កុំនាំវាមក វាពុំមែនជាចៅអញទេ

- ប៉ា ! កូនរបស់ខ្ញុំបាទ ម្តេចក៏ពុំត្រូវជាចៅរបស់ប៉ា ?

- មិនមែនចៅអញទេ ព្រោះវាមិនមែនជាកូនដែល កើតមកពីមនុស្សដែលអញត្រូវការឲ្យវាកើត - អញមិនទទួល ស្គាល់វាថាជាចៅអញទេ

- ប៉ា ចុះម៉េចក៏ប៉ាមានប្រសាសន៍អញ្ចឹង !

– ព្រោះអញបានដណ្តឹងកូនគេម្នាក់ ទុកឲ្យឯងរួចទៅហើយ ។ គេជាមនុស្សដែលមានចរិយាសណ្តាប់ធ្នាប់ល្អគ្រប់បែប គ្រប់យ៉ាង – ឯងចង់ដឹងថានារីនោះជានរណាទេ ?

– ទេ ណ្ហើយចុះប៉ា កុំប្រាប់ខ្ញុំបាទធ្វើអ្វី ខ្ញុំបាទអត់ចង់ដឹងទេ

– តែកូនឯងត្រូវតែត្រឡប់ទៅស្រុកវិញ

– បាទ ប៉ា ខ្ញុំបាទ នឹងត្រឡប់ទៅវិញជាមួយប៉ា

– តែឯងត្រូវទៅតែម្នាក់ឯង ប្រពន្ធកូនយកទៅមិនបានទេ

– ចុះប៉ាឲ្យខ្ញុំបាទ ទោលប្រពន្ធកូនរបស់ខ្ញុំបាទ យ៉ាងដូចម្តេចកើត សូម្បីតែប៉ាក៏នៅតែទោលខ្ញុំបាទពុំកើត ប៉ាស្ទិតបាកអញ្ជើញមកតាមខ្ញុំបាទដល់បាងកកនេះ ក៏ព្រោះខ្ញុំបាទ ជាកូនប៉ា – បើអញ្ចឹងម៉េចក៏ប៉ាឲ្យខ្ញុំបាទ ទោលប្រពន្ធកូនរបស់ខ្ញុំទៅវិញ ?



– តែក្នុងពេលនេះ អញត្រូវតែនាំឯងទៅវិញ គឺត្រូវប្រើអំណាច បើនិយាយនឹងទៅ ឯងបេះតែមានលេសហោះដោះសារជានិច្ច – ឯងមានហេតុផលរបស់ឯង អញក៏មានហេតុផលរបស់អញដែរ – ដរាបណាអញនៅមានជីវិត ដរាបនោះអញគឺនៅជាឪរបស់ឯងដែរ អញមានអំណាចលើឯងជាកូន – អញមិនចង់ប្រើអំណាចទេ តែបើមានការចាំបាច់ត្រូវអញប្រើអំណាចក៏ប្រើដែរ . . .

– ប៉ា ឲ្យខ្ញុំបាទធ្វើម៉េច ?

– ត្រូវទៅផ្ទះយន្តហោះត្រឡប់ទៅស្រុកវិញជាមួយអញនៅពេលព្រឹកស្អែកនេះ

– ប៉ា ទិញសំបុត្ររួចហើយឬ ?

– អញចាត់ចែងទិញរួចស្រេចអស់ហើយ

– ចុះ លិខិតឆ្លងដែន ?

– អញ ធ្វើរួចហើយ

- បើអញ្ចឹង ខ្ញុំបាទសុំទៅប្រាប់ប្រពន្ធកូនសិន

- មិនបានទេ! ឯងនឹងចេញពីបន្ទប់នេះមិនបានដាច់ខាត មុនពេលឡើងយន្តហោះ

- បើអញ្ចឹង ខ្ញុំបាទសុំឲ្យអ្នកបំរើហូតែលទៅហៅប្រពន្ធកូនខ្ញុំបាទមកកន្លែងនេះ

- មិនបាន! មិនបាច់ជួបគ្នា ហើយលាគ្នាទេ — ទៅឡើងយន្តហោះស្ងៀម ៗ តែម្តងទៅ

- ប៉ា - ម៉េចក៏ប៉ាធ្វើអញ្ចឹង!

- ព្រោះគ្មានផ្លូវអើក្រៅពីនេះ អញនិយាយស្រួលមកយូរហើយ គ្មានបានផលប្រយោជន៍អីសោះ — ពេលនេះអញត្រូវធ្វើដូច្នេះ — អាសាច់មួយដុំ បើនឹងបោះចោលឲ្យឆ្កែស៊ីទៅក៏ដូចជានៅស្អុយ — បំណាច់អញខំមកតាមប៉ុណ្ណេះហើយ អញត្រូវតែនាំឯងទៅវិញឲ្យទាល់តែបាន — អញមកម្នាក់ឯងក្រែងចាប់ឯងពុំឈ្នះ បានជាអញនាំបងប្រុសឯងមកជាមួយ



ផង - បើឯងមិនព្រមឡើងយន្តហោះទេ អញនឹងបងឯងក៏ត្រូវតែចាប់ឯងម្នាក់ម្នាក់អូសទៅឲ្យទាល់តែបាន - បើឯងហ៊ានកកៃផឹងនឹងអញជាឪឯងក៏តាមចិត្តឯងទៅចុះ ឬបើឯងហ៊ានស្រែកឡូឡាឲ្យគេមួតចាប់អញនឹងបងឯងនោះ ក៏ស្រេចតែចិត្តឯងទៅចុះ តែពាក្យដាច់ខាតរបស់អញគឺមិនព្រមឲ្យឯងចេញពីបន្ទប់ហូតែលនេះមុនពេលឡើងយន្តហោះ

- ចុះធ្វើម៉េច នឹងឲ្យប្រពន្ធកូនរបស់ខ្ញុំបាទ បានដឹងផងប៉ា ?

- ឯងសរសេរសំបុត្រឲ្យដំណឹងទៅកាទៅ អញឲ្យអ្នកបំរើហូតែលយកទៅឲ្យរកតាំងសំបុត្រតាំងឡាន ។

ឪពុករបស់ខ្ញុំបានបណ្ដាប់បងប្រុសរបស់ខ្ញុំឲ្យចាត់ចែងរៀបចំអីវ៉ាន់ ។ ខណៈនោះ បងប្រុសរបស់ខ្ញុំក៏ដើរចេញទៅក្រៅបាត់ទៅ ។ ឪពុករបស់ខ្ញុំក៏ក្រោកដើរទៅចាក់សោបន្ទប់ ហើយក៏ដកកូនសោយកទៅដាក់ក្នុងហោប៉ៅអាវរបស់លោក ។

– កូន ! (ឪពុករបស់ខ្ញុំនិយាយ) បើកូនឯងចង់ផ្តើមកូនសោពីប៉ា ហើយដាក់សោបើកទ្វារតែចេញទៅក៏បាន តែប៉ាបានសំរេចចិត្តថា បើប៉ានៅពុំទាន់ស្លាប់ទេនោះ កូនឯងមិនផ្តើមយកកូនសោនេះ ពុំបានជាដាច់ខាត . . .

ពិតណាស់ហើយ ខ្ញុំមុខជាពុំហ៊ានផ្តើមយកកូនសោនោះឡើយ ។ ខណៈនោះខ្ញុំគិតថា បើទុកជាខ្ញុំខំនិយាយអង្វរករឪពុករបស់ខ្ញុំយ៉ាងណាក៏ពុំមានបានផលអ្វីដែរ ព្រោះខ្ញុំធ្លាប់បានដឹងនិស្ស័យចិត្តថ្មើមរបស់លោក ប្រសិនបើលោកតាំងចិត្តធ្វើអ្វីហើយ គ៏គ្មានអ្វីទៅជំទាស់លោកបានឡើយ ។

ការដែលខ្ញុំត្រូវធ្វើក្នុងពេលនេះ គឺមានតែមួយគត់ គឺ ត្រូវសរសេរសំបុត្រឲ្យដំណឹងទៅនាង យូរ៉េត តាមសេចក្តីអនុញ្ញាតពីឪពុករបស់ខ្ញុំ ។ ខ្ញុំក្រោកដើរទៅរកតុ ហើយក៏អង្គុយសរសេរសំបុត្រដោយពុំនិយាយស្តីអ្វីជាមួយនឹងឪពុករបស់ខ្ញុំតទៅទៀត ។



ខ្ញុំពុំចាំបាច់និយាយថា ខ្ញុំសរសេរសំបុត្រទៅប្រាប់នាង យូរ៉េត ជាដូចម្តេចខ្លះឡើយ . . . ខ្ញុំបានសរសេរការពិតគ្រប់បែបគ្រប់យ៉ាងប្រាប់នាង . . . ការដែលខ្ញុំស្តាយក្នុងចិត្តជាខ្លាំងនោះ គឺគឺខ្ញុំត្រូវព្រាត់ប្រាសគ្នាដោយពុំបានឃើញមុខ . . . ខ្ញុំបានប្រាប់នាងថា ខ្ញុំពុំអាចទិញរបស់លេងយកទៅធ្វើកូនលេងតាមពាក្យដែលនាងបានផ្តាំនោះបានឡើយ . . . ខ្ញុំបានអង្វរករនាងថា សុំកុំឲ្យនាងខឹងសម្បារនឹងឪពុករបស់ខ្ញុំ ព្រោះការដែលលោកធ្វើដូច្នេះ គឺដោយសារតែលោកស្រឡាញ់រូបខ្ញុំដែលជាកូននោះឯង . . .

ខ្ញុំត្រូវសរសេរសំបុត្រនោះវែងណាស់ គឺត្រូវសរសេររៀបរាប់មកតាំងពីដើម ព្រោះខ្ញុំធ្លាប់បានប្រាប់នាង យូរ៉េត ថា សំរាប់ឪពុករបស់ខ្ញុំនោះមិនជាអ្វីប៉ុន្មានទេ ។ ខ្ញុំត្រូវលើកយករឿងចាស់មកនិយាយសារជាថ្មីទៀត ។ ខ្ញុំបានប្រាប់នាងថា សុំឲ្យនាងត្រឡប់ទៅភ្នំពេញវិញ ហើយទៅនៅ

ជាមួយមិត្តភ័ក្តិរបស់ខ្ញុំ ដោយកុំឲ្យអ្នកណាដឹង ហើយពឹងពាក់មិត្តភ័ក្តិនោះ ឲ្យទៅខ្សឹបប្រាប់ខ្ញុំ ។

ខ្ញុំអង្គុយសរសេរសំបុត្រនោះអស់ពេលពីរម៉ោងទើបចប់ ។ ខណៈនោះ បងប្រុសរបស់ខ្ញុំក៏បានត្រឡប់មកវិញជាមួយនឹងអីវ៉ាន់ជាច្រើន ។ ខ្ញុំមើលនាឡិកាឃើញម៉ោងមួយកន្លះហើយ ។ បងប្រុសរបស់ខ្ញុំបាននិយាយការអ្វីដែលខ្ញុំស្តាប់ពុំបាន រឿង ៗ ជាមួយនឹងឪពុករបស់ខ្ញុំ ។ មួយសន្ទុះក្រោយមកឪពុករបស់ខ្ញុំក៏ទារយកសំបុត្រដែលខ្ញុំសរសេរ និងកូនសោរថយន្តពីខ្ញុំ ដោយប្រាប់ថា ឲ្យបងប្រុសរបស់ខ្ញុំយករបស់ទាំងនោះទៅពឹងពាក់អ្នកបំរើហ្វូគែលឲ្យយកទៅឲ្យនាង យូរ៉េត ។ ខ្ញុំក៏បានប្រគល់សំបុត្រនិងកូនសោរថយន្តឲ្យទៅបងប្រុសរបស់ខ្ញុំ ។ បងប្រុសរបស់ខ្ញុំក៏បានចេញពីបន្ទប់នោះម្តងទៀត ។ ឪពុករបស់ខ្ញុំបង្គាប់ឲ្យខ្ញុំបិទភ្លើងអគ្គិសនីក្នុងបន្ទប់ ហើយយើងនឹងសម្ងំដេកស្ងៀមរៀងខ្លួន ។



ប្រហែលជាពីរម៉ោងក្រោយមក បងប្រុសរបស់ខ្ញុំ ក៏ត្រឡប់មកវិញ ហើយខ្សឹបដាក់ឪពុករបស់ខ្ញុំថា កិច្ចការទាំងអស់បានសំរេចរៀបរយអស់ហើយ ។

យប់នេះខ្ញុំដេកពុំលក់សោះ ។ ការគិតមួយម៉ឺនមួយសែនចំពូកបានផុសចេញពីចិត្តរបស់ខ្ញុំ តែជាការគិតដែលគ្មានបានការអ្វី ។ តាមពិតក្នុងពេលយប់នោះ ខ្ញុំគិតអ្វីពុំផុះឆ្ងាយសោះឡើយ ។ ខ្ញុំដូចជាគ្មានកំឡាំងចិត្តនៅក្នុងខ្លួនសោះ ។ ខ្ញុំមានសង្ឃឹមតែម្យ៉ាងថា នាង យូរ៉េត នឹងទៅតាមខ្ញុំឯកឯងពេញ តែក៏ជាសេចក្តីសង្ឃឹមដែលពុំពិតប្រាកដ ។ ខ្ញុំគិតម្យ៉ាងទៀតថា ប្រសិនបើនាង យូរ៉េត បានដឹងរឿងការដូច្នេះ ប្រហែលជានាងពុំទៅតាមខ្ញុំទេ ។ ខ្ញុំដូចជាគេជះពុំបាន ស្មានពុំត្រូវខ្វែកការពិបាកចិត្តរបស់ខ្ញុំ ។ ខ្ញុំព្រមទទួលចុះចាញ់ចំពោះកម្លាំងចិត្តរបស់ឪពុកខ្ញុំ ។ ខ្ញុំពុំទទឹងរឹងរូស ឬ គេចវៀសអ្វីទាំងណោកឡើយ ។

ខ្ញុំនឹកការណ៍តនាង យូរ៉េត និង យូរ៉ា ស្ទើរតែដាច់ខ្យល់ស្លាប់ ។ ខ្ញុំនឹកថា នាង យូរ៉េត មុខជាចាំមើលផ្លូវខ្ញុំទាល់តែយប់ជ្រៅជាពុំខាន ព្រោះខ្ញុំពុំបានប្រាប់នាងថា ខ្ញុំទៅណាផង ។ ខ្ញុំនឹកគូរសភាពនាងថា កាលបើនាងចាំមើលផ្លូវខ្ញុំទាល់តែយប់ជ្រៅហើយពុំឃើញខ្ញុំត្រឡប់ទៅផ្ទះវិញទេនោះ នាងមុខជាអន្ទះអន្ទែងរន្ធត់ចិត្តជាខ្លាំងពុំខាន ។

តែពុំដឹងជាហេតុអ្វី ពេលនេះទឹកចិត្តរបស់ខ្ញុំបែរទៅនឹកដល់ដើមគគីរមួយដើមធំ ដែលដុះតាមផ្លូវជិតដល់ផ្ទះរបស់ខ្ញុំ ។ ខ្ញុំធ្លាប់ឃើញដើមគគីរនោះរាល់ថ្ងៃ តែពុំដែលបាននឹកនាថាជាដើមឈើសំខាន់អ្វីសោះឡើយ ចុះពេលនេះ ពុំដឹងជាមានហេតុអ្វីមកជំរុញចិត្តរបស់ខ្ញុំឲ្យបែរទៅនឹកដល់ដើមគគីរនោះ...

លុះដល់ពេលល្ងើ ៗ ជិតនឹងលក់ ខ្ញុំក៏ស្រមៃឃើញដើមគគីរនោះម្តងទៀត ហើយហាក់ដូចជាមានសំឡេងអ្វីមួយមកខ្សឹបដាក់ត្រចៀកខ្ញុំថា "ដើមគគីរធំ" ហេតុអ្វីក៏ដូច្នេះ?



អ្វីជាហេតុបណ្តាលឲ្យមនោគតិរបស់ខ្ញុំគួបទៅដល់ដើមគគីរនោះ? អ្វីមកខ្សឹបដាក់ត្រចៀករបស់ខ្ញុំយ៉ាងនេះ? ខ្ញុំក៏ពុំដឹង-ពុំយល់ពុំចូលចិត្តទាល់តែសោះ ។

ម៉ោង ៦ គត់... ។ ឪពុករបស់ខ្ញុំ និងបងប្រុសរបស់ខ្ញុំ បាននាំខ្ញុំចុះពីសណ្ឋាគារ តេងៈកាស៊ិន ធ្វើដំណើរឆ្ពោះទៅកាន់ចំណតអាកាសយាន ដូនមឿង ដែលនឹងត្រូវធ្វើដំណើរត្រឡប់ទៅភ្នំពេញវិញនៅវេលាម៉ោងប្រាំពីរកន្លះ ។ ខ្ញុំលែងមុខស្ទើរតែទប់ខ្លួនពុំជាប់ ។ ខ្ញុំគិតថា ប្រសិនបើអ្នកដទៃក្រៅពីឪពុកហ៊ានមកធ្វើដូច្នេះ មុខជាមានការកាប់សម្លាប់គ្នាជាពុំខាន ។ តែនេះ ព្រោះតែជាឪពុក ហើយការដែលលោកហ៊ានធ្វើយ៉ាងនេះ ក៏មកតែពីលោកស្រឡាញ់ខ្ញុំជាកូន ។ លុះគិតដូច្នេះហើយ ខ្ញុំក៏ត្រូវតែយល់ដល់ចិត្តថ្មី នឹងហេតុផលរបស់លោក សូម្បីហេតុផលនោះពុំត្រូវគ្នា ពុំស្របគ្នានឹងហេតុផលរបស់ខ្ញុំក៏ដោយ ។

ឪពុកខ្ញុំយល់ថាធ្វើដូច្នេះ ជាអត្ថប្រយោជន៍ដល់ខ្ញុំជាកូន តែចំពោះរូបខ្ញុំវិញ ខ្ញុំយល់ថាការធ្វើបែបនេះជាអំពើការុណ-កម្មយ៉ាងខ្លាំងក្រៃណាខ្លាំង ។ មនុស្សដែលអាចធ្វើបែបនេះ ជាមួយខ្ញុំបាន ក៏មានតែម្នាក់ប៉ុណ្ណោះ គឺឪពុករបស់ខ្ញុំ ឯអ្នកដទៃវិញធ្វើពុំបានជាដាច់ខាត ។

ខណៈខ្លះ ខ្ញុំដូចជាមួម៉ៅក្តៅក្រហាយចិត្តជាខ្លាំងចំពោះវាសនាអាក្រក់របស់ខ្ញុំ ព្រោះជីវិតរបស់ខ្ញុំចេះតែជួបប្រទះនូវរឿងរ៉ាវប្លែកៗ ពុំដូចគេសោះ ។ អ្នកដទៃធ្លាប់តែមានរឿងរ៉ាវថា កូនក្រមុំរត់តាមកូនកំលោះ ហើយឪពុកម្តាយខាងស្រីទៅតាមយកកូនក្រមុំមកវិញ តែរឿងរ៉ាវរបស់ខ្ញុំ ជារឿងរ៉ាវដែលកូនកំលោះរត់តាមកូនក្រមុំ ហើយឪពុកមកចាប់ស្ទួសយកកូនកំលោះទៅវិញ ។ ការដែលខ្ញុំត្រូវប្រើពាក្យថា " ចាប់ស្ទួស " ក៏ព្រោះនៅពេលចេញពីសណ្ឋាគារទៅឡើងយន្តហោះនោះ ឪពុករបស់ខ្ញុំបានកាន់ដៃខ្ញុំជាប់ ពុំព្រមលែង



សោះឡើយ ។ ក្នុងពេលនោះរូបខ្ញុំដូចជាកូនក្មេងដែលគេចខ្លួនពីផ្ទះ ព្រោះឪពុកដើររកឃើញក៏ស្ទួសដៃយកទៅផ្ទះវិញដូច្នោះដែរ ។ ក្នុងពេលនោះប្រសិនបើខ្ញុំស្រែកឡូឡាឡើង រឿងរ៉ាវរបស់ខ្ញុំមុខជាក្លាយទៅជាអាហាររបស់តម្រួត ឬរបស់អ្នកសារពត៌មានទៅហើយ ។

ការចំឡែកម្យ៉ាង ដែលខ្ញុំគិតពុំយល់គឺលិខិតឆ្លងដែន ។ នៅពេលទៅដល់ស្ថានីយ៍អាកាសយាន ដូនមឿង ឪពុករបស់ខ្ញុំបានយកលិខិតឆ្លងដែនបីទៅចុះទិដ្ឋាការ ។ លិខិតឆ្លងដែនមួយជារបស់ឪពុកខ្ញុំ មួយទៀតជារបស់បងប្រុសខ្ញុំ ហើយលិខិតទីបីជារបស់ខ្ញុំ រូបថតរបស់ខ្ញុំ តែឈ្មោះវិញពុំមែនឈ្មោះរបស់ខ្ញុំឡើយ ។ ប៉ុន្តែខ្ញុំត្រូវបិទមាត់ពុំស្តីអ្វី ពុំសាកសួរអ្វី ចេះតែបណ្តោយខ្លួនឲ្យរឿងរ៉ាវនោះ នៅជារឿងរ៉ាវអាថ៌កំបាំង ដែលខ្ញុំក៏ពុំបានដឹងថាជាយ៉ាងដូចម្តេចដែរ ។

## វគ្គទី ១៥

# ធុញព្រួយព្រោះព្រាត់

សភាពនៃចិត្តរបស់ខ្ញុំនៅពេលឡើងជិះយន្តហោះ ដូចជាពិបាកអធិប្បាយឲ្យត្រូវបាន ព្រោះមានទុក្ខកង្វល់ខ្លាំងពេក ៗ ខ្ញុំស្រក់ទឹកភ្នែកក្នុងកាលដែលគិតថា វិនាទីនេះ ជាវិនាទីដែលខ្ញុំត្រូវព្រាត់ប្រាសនឹកសាកប្រពន្ធជាទីស្នេហា និង កូនសំឡាញ់ដែលទើបនឹងចេះសើចចេះការ ៗ

ឪពុករបស់ខ្ញុំបាននិយាយលេងជាមួយខ្ញុំ ហាក់ដូចជាគ្មានរឿងអ្វីកើតឡើង ៗ លោកនិយាយដល់ការធ្វើដំណើរតាមផ្លូវទឹកផ្លូវគោកនិងផ្លូវអាកាស និងការដើរលេងនៅក្រុងបាងកក ដោយបានប្រើពាក្យពេចន៍ពីរោះពិសា និង មេត្តាករុណាចំពោះខ្ញុំ ដែលនាំឲ្យខ្ញុំយល់ថា ឪពុករបស់ខ្ញុំមានជ័យជំនះលើរូបខ្ញុំហើយ ៗ

មួយសន្ទុះក្រោយមក ហូតែស្យយន្តហោះបាននាំយក



ទស្សនាវដ្តី និងសារពត៌មានគ្រប់យ៉ាងមកចែកអ្នកដំណើរ អានកំសាន្តដើម្បីរំលាប់ពេលវេលា នៃការធ្វើដំណើរកុំឲ្យធុញទ្រាន់ ខ្ញុំបានទទួលសារពត៌មានដែលចេញព្រឹកនេះមកអានលេង ៗ ខ្ញុំបានជួបនឹងហេតុការណ៍ដ៏ចំឡែកគួរឲ្យកើបចិត្ត ដែលខ្ញុំត្រូវពិនិត្យហើយពិនិត្យទៀត ៗ

សារពត៌មាននោះ ជាសារពត៌មានចេញផ្សាយកាលព្រឹកនៅទីក្រុងបាងកក ជាសារពត៌មានដែលសមនឹងឈ្មោះជា "អរុណបាងកក" ៗ គេដាក់ចំណងជើងធំ ៗ ថា " ដំណឹងពិសេសនៅម៉ោង ៤ ទៀបភ្លឺ ៗ សារពត៌មាននេះបានអួតថាគេបានដំណឹងពិសេសមួយនៅម៉ោង ៤ ទៀបភ្លឺ ហើយគេក៏យកមកចុះផ្សាយក្នុងទំព័រសារពត៌មានរបស់គេនៅពេលអរុណរះ ៗ គេនិយាយថា ដំណឹងពិសេសនេះគឺហេតុការណ៍ដ៏សំខាន់ដែលកើតឡើងកាលពីពេលម៉ោង ៤ ភ្លឺ ហើយត្រូវប្រាកដរូបឡើងនៅក្នុងទំព័រសារពត៌មានរបស់គេ ដែលអាច

ធ្វើឲ្យអ្នកអានបានដឹងដំណឹងនេះនៅពេលឥណោះ ៗ សភាពដែលគាប់ស្រូបទាញក្រសែភ្នែក នឹងសតិអារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំងនោះ ក៏គឺដំណឹងអំពីមរណភាពនៃរូបខ្ញុំផ្ទាល់ខ្លួនឯង ៗ

ខ្ញុំត្រូវឈឺភ្នែកក្នុងខណៈដែលខ្ញុំបានអានដំណឹងនេះ...

ខ្ញុំសង្ស័យខ្លួនឯងថា ក្រែងភ្នែករបស់ខ្ញុំកាន់ប្រឡំ ឬ ក៏ស្មារតីរបស់ខ្ញុំពុំប្រក្រតីទេដឹង ? ព្រោះប្រសិនបើខ្ញុំនៅមានសតិសម្បជញ្ញៈនឹងខុសត្រូវដូចមនុស្សធម្មតានោះ ខ្ញុំក៏មុខជាពុំបានឃើញដំណឹងដូច្នេះនៅលើទំព័រសារពត៌មាន ឬក៏មានមនោ-សញ្ចេតនាដូចពេលនេះឡើយ ...

ដំណឹងនេះ ពុំមែនជាដំណឹងតូចតាចទេ គឺជាដំណឹងធំដុំណាស់ ៗ គេបានសរសេរឈ្មោះខ្ញុំធំៗ ហើយយ៉ាងត្រឹមត្រូវនៅលើទំព័រសារពត៌មាន ។ គេនិយាយថា ខ្ញុំបានបើកបររថយន្តចូលទីក្រុងបាងកក ដើម្បីជួបនឹងញាតិមិត្រ ដែលសំណាក់នៅសណ្ឋាគារ រតនៈកោស៊ិន លុះត្រឡប់មកវិញ



ខ្ញុំបានបើកបររថយន្តធ្លាក់ចេញពីផ្លូវថ្នល់ ហើយជ្រុលទៅពុកដើមគគីរយ៉ាងខ្លាំង ពាល់តែបណ្ដាលឲ្យមានភ្លើងឆេះរថយន្តនិងម្ចាស់ខ្ទេចខ្ទីអស់ គេបញ្ជាក់ថា ហេតុការណ៍នេះកើតឡើងប្រមាណជាម៉ោង ៣ ប្រហែលជាម៉ោង ៤ នាង យុវ៉ែត ប្រពន្ធខ្ញុំក៏យកក្នុងការបាត់ប្ដីពុំឃើញត្រឡប់មកផ្ទះវិញ ក៏នាងចេញទៅតាមរកប្ដី លុះទៅដល់ត្រង់កន្លែងដែលរថយន្តត្រូវភ្លើងឆេះនោះ នាងក៏សង្ស័យថា ជារថយន្តរបស់ប្ដីនាង ហើយនាងក៏ចូលទៅមើលសំណាករថយន្តនោះ ជារថយន្តរបស់ប្ដីនាងមែន ហើយសាកសពដែលត្រូវភ្លើងឆេះកេលខ្មៅដូចមនៅក្នុងរថយន្តនោះ ក៏នាងសន្និដ្ឋានថាជាសាកសពរបស់ខ្ញុំ ដែលជាប្ដីនាងដែរ — អ្នកនិពន្ធសារពត៌មាន បានសន្និដ្ឋាននៅចុងខាងក្រោយថា ប្រហែលជាខ្ញុំស្រវឹងស្រា ហើយបើកបររថយន្តលឿនពេក បានជាមានគ្រោះថ្នាក់ខ្លួនឲ្យស្លាប់ស្ងួនយ៉ាងនេះ ។

នេះ, ស្អីចេះ! ... (ខ្ញុំគិត) រូបខ្ញុំនៅជារូបខ្ញុំដដែល ម្តេចក៏ថាខ្ញុំស្លាប់? ... ឬថាជាបិសាចរបស់ខ្ញុំដែលស្លាប់ទៅហើយ? ... បើតាមខ្ញុំធ្លាប់បានដឹងមកថា សារពត៌មាននេះ ពុំដែលចុះផ្សាយដំណឹងភូតភរកុហកផ្តេសផ្តាសឡើយ ហើយដំណឹងបែបនេះ ក៏ពុំងាយនឹងមានអ្នកណាហ៊ានកុហកលេងផ្តេសផ្តាសបានដែរ ព្រោះហេតុការណ៍បានកើតឡើងនៅក្នុងក្រុងបាងកកនោះឯងដែលកំពុងធ្វើយុទ្ធ ទីស្នាក់-ស្នាមផ្សេង ៗ ក៏មុខជាមានសល់នៅក្នុងនោះ ហើយបើជនានុជនចង់ទៅមើល ក៏អាចទៅមើលបានដោយងាយដែរ ។

ក្នុងខណៈដែលខ្ញុំកំពុងតែសង្ស័យនឹងខ្លួនឯងនោះ បងប្រុសរបស់ខ្ញុំក៏សំឡឹងមើលមុខខ្ញុំហាក់ដូចជាចង់ដឹងនូវការពិតអ្វីម្យ៉ាងពីខ្ញុំ ។

- បង! (ខ្ញុំសួរ) បងដឹងហើយនៅ?

- ដឹងអ្វី? (បងខ្ញុំសួរមកវិញ)



ខ្ញុំហុចកាសែតជូនបងខ្ញុំ ។ បងខ្ញុំក៏អានយ៉ាងពិនិត្យពិច័យ ។ ខ្ញុំស្ងៀមចាំទាល់តែបងខ្ញុំអានចប់ ទើបខ្ញុំសួរថា :

- មើលឃើញបង ?

- ឃើញ! កាសែតនេះផ្សាយដំណឹងរហ័សមែន ...

- បងដឹងឬទេ ថារឿងនេះយ៉ាងម៉េចខ្លះ ?

បងប្រុសរបស់ខ្ញុំ បានសំឡឹងមើលមុខខ្ញុំ ដោយក្រសែភ្នែកដែលពោរពេញទៅដោយសេចក្តីអាណិតអាសូរ ។ បងខ្ញុំអង្អែលស្មាខ្ញុំតិចៗ ថ្នមៗ ហើយក៏និយាយរឿងរ៉ាវទាំងអស់ប្រាប់ខ្ញុំ ។

រឿងរ៉ាវដែលនិយាយនោះ រួមសេចក្តីថាលោកឪពុកនិងបងខ្ញុំបានទៅដល់ទីក្រុងបាងកកនេះប្រាំថ្ងៃហើយ ។ ក្នុងកំឡុងពេលប្រាំថ្ងៃនេះ បងខ្ញុំបានទៅលបមើលការប្រព្រឹត្តទៅរបស់ខ្ញុំដឹងអស់ហើយ ។ បានឃើញនាង យូវ៉េត បានឃើញខ្ញុំ បានឃើញកូនខ្ញុំ បានឃើញការរស់នៅរបស់គ្រួសារខ្ញុំ

និងអ្វីៗគ្រប់សព្វទាំងអស់ ។ ឪពុករបស់ខ្ញុំបានសំរេចចិត្តថា ត្រូវតែនាំយករូបខ្ញុំត្រឡប់ទៅស្រុកវិញឲ្យទាន់តែបាន ហើយ ត្រូវប្រើកលឧបាយដោយវិធីណាមួយ ធ្វើឲ្យនាង យូរ៉េត អស់សង្ឃឹម ដើម្បីកុំឲ្យនាងតាមទៅរកខ្ញុំឯភ្នំពេញទៀត ។

រឿងនេះឪពុកខ្ញុំជាអ្នកគិត បងប្រុសខ្ញុំជាអ្នកធ្វើ ។ អ្នកគិតក៏ពូកែ អ្នកធ្វើក៏អង់អាចក្លាហាន បានជាធ្វើបានសំរេចយ៉ាងនេះ ។ ការនេះត្រូវប្រើចិត្តដាច់ខាត ត្រូវធ្វើដោយក្លាហានពុំខ្លាចបាប ។ ពិតណាស់ហើយការពង្រាត់បង្រាសកូនប្រពន្ធរបស់អ្នកណាមួយនោះ ជាការពិបាកណាស់ ។ អ្នកដែលហ៊ានធ្វើ គឺទាល់តែជាអ្នកដែលមានកំឡាំងចិត្តរឹងប៉ឹងមែនទែនណាស់ដែរ ។ កាលបើគេមានកំឡាំងចិត្តមុតហ៊ានពង្រាត់បង្រាសប្រពន្ធកូនអ្នកដទៃបានយ៉ាងនេះហើយ គេក៏អាចធ្វើបាបកម្មដទៃទៀត មានឃាតកម្មជាដើមបានយ៉ាងស្រួល ។



លុះបានស្ដាប់រឿងរ៉ាវទាំងអស់នេះហើយ ខ្ញុំក៏ព្រមទទួលសារភាពថា ឪពុកនិងបងប្រុសរបស់ខ្ញុំពូកែជាងខ្ញុំមែន ព្រោះលោកទាំងពីរហ៊ានធ្វើនូវអំពើដែលខ្ញុំពុំហ៊ានធ្វើ ។ ខ្ញុំបានលើកដៃទាំងពីរឡើងលើ ហើយសូមចុះចាញ់លោកទាំងពីរនេះហើយ ។

គំនិតពង្រាត់បង្រាសនេះ ដោយពុំចង់ឲ្យនាង យូរ៉េត ទៅតាមនោះ លោកត្រូវធ្វើឲ្យនាងជឿថា ខ្ញុំស្លាប់បាត់ទៅហើយ ។ ក្នុងកំឡុងពេលពីរម៉ោង ដែលបងប្រុសខ្ញុំបានចេញពីបន្ទប់សណ្ឋាគារ រេតឆេកោស៊ិង ដើម្បីទាត់ការយកសំបុត្រនិងរថយន្តរបស់ខ្ញុំទៅប្រគល់ឲ្យនាង យូរ៉េតនោះ បងខ្ញុំបានទៅធ្វើបាបកម្មមួយដែលមានទម្ងន់ធ្ងន់ ។ បងខ្ញុំបានបើករថយន្តរបស់ខ្ញុំ ទៅទិញប្រេងសាំងពី ម៉ាកយក ដាក់លើរថយន្ត ហើយបើកសំដៅទៅផ្ទះរបស់ខ្ញុំ ។ តាមផ្លូវជួបទៅផ្ទះរបស់ខ្ញុំនេះ មានបណ្ដៀងអគ្គីសនីបំភ្លឺតែពាក់កណ្ដាល

ផ្លូវចុះណោះ ពាក់កណ្ដាលផ្លូវទៀតនោះងងឹតណាស់ ព្រោះឆ្ងាយពីក្រុង ។ ពេលយប់តែងមានមនុស្សដើរទៅមកពុំសូវដាច់ ។ អ្នកបើកបររថយន្តត្រូវប្រុងប្រយ័ត្នឲ្យមែនទែនទើបបាន សូម្បីតែខ្ញុំដែលបើកបររថយន្តតាមផ្លូវនោះរាល់ថ្ងៃក៏នៅតែមានគ្រោះថ្នាក់ច្រើនដងណាស់ហើយ ។ ជាពិសេសទៅទៀត ប្រសិនបើមានរថយន្តមកពីខាងមុខហើយបើកភ្លើងនោះ គឺរឹតតែមានគ្រោះថ្នាក់ច្រើនឡើងទៀត ព្រោះវាបាំងភ្នែកមើលអ្នកដើរពុំឃើញ ហើយប្រសិនបើតាំងចិត្តបុកមនុស្សអ្នកដើរផងនោះ ក៏ជាការងាយណាស់ទៅទៀត ។

នេះជាអំពើដែលបងប្រុសរបស់ខ្ញុំបានធ្វើ ជាអំពើដ៏អាក្រក់លាមក តែបងខ្ញុំក៏ចាំបាច់ត្រូវតែធ្វើ ដើម្បីឲ្យបានសំរេចនូវលទ្ធផលសមតាមផែនការរបស់ឪពុកខ្ញុំ ។ ក្នុងពេលដែលបងខ្ញុំយករថយន្តរបស់ខ្ញុំបើកបរទៅនោះ ជាពេលក្រោយអាធ្រាត្រ ជាពេលស្ងាត់ កាលបើបងខ្ញុំបានជួបនឹងអ្នកដំណើរណា



ដែលដើរតែម្នាក់ឯង បងខ្ញុំក៏បើករថយន្តបុក បុកល្មមតែដួលសន្លប់កុំឲ្យមានឈាម ហើយក៏បញ្ឈប់រថយន្តចុះទៅលើកយកមនុស្សអ្នករងគ្រោះនោះទៅដាក់លើរថយន្ត ហើយក៏បើកបរតទៅទៀត ។ លុះទៅដល់កន្លែងដែលមានដើមគគីរធំដែលផ្លូវចុះត្រង់នោះបន្តិច បងខ្ញុំក៏បញ្ឈប់រថយន្ត ទាញអ្នករងគ្រោះដាក់ចំចង្កូត ហើយក៏ដាក់លេខបញ្ចេញឲ្យរថយន្តលឿនទៅបុកដើមគគីរនោះ រួចក៏គូសឈើគូសដុតរថយន្តនោះចោលទៅ ។ ដោយយកខ្សែប្រេងសាំងពីរហ៊ុក និងប្រេងសាំងក្នុងធុងបំពង់នោះ ភ្លើងក៏ត្រូវឆាបឆេះឡើងភ្លាមយ៉ាងខ្លាំងសន្ធោសន្ធៅ ល្មមឆេះទាំងរថយន្ត ទាំងមនុស្សឲ្យក្លាយទៅជាផេះបាន ។

— អូន ! ( បងប្រុសខ្ញុំបានពោលក្នុងពេលដែលបាននិយាយរឿងរ៉ាវប្រាប់ចប់ហើយ ) រឿងរ៉ាវមានត្រឹមតែប៉ុណ្ណឹង . . .

— ត្រឹមតែប៉ុណ្ណឹង! (ខ្ញុំនិយាយជួនពាក្យ) បងនិយាយដូចជាធ្វើលេង ដូចជាថារឿងដែលបងធ្វើនោះ ជារឿងតូចតាចបន្តិចបន្តួច — បង! ចុះបងខំធ្វើអញ្ចឹង តើដើម្បីប្រយោជន៍អ្វី?...

— ដើម្បីឲ្យប្រពន្ធរបស់ឯងជឿជាក់ថា អូនឯងពិតជាស្លាប់ ហើយកលែងវិលវល់នឹកនាដល់អូនឯងទៀត...

— ចុះប៉ាក្ដី បងក្ដី អាចត្រាំអន្ទុយចាំយាមល្បាតរូបខ្ញុំមួយជីវិតឬយ៉ាងណា? ព្រោះអី ខ្ញុំអាចសរសេរសំបុត្រផ្ញើទៅប្រាប់ប្រពន្ធខ្ញុំវិញថា រូបខ្ញុំនៅរស់ ហើយមនុស្សដែលស្លាប់នោះពុំមែនជារូបខ្ញុំទេ ខ្ញុំត្រឡប់ទៅបាងកកវិញ ទៅនាំយកប្រពន្ធខ្ញុំមកក៏ស្រេចទៅហើយ...

— រឿងនេះបងជឿជាក់ថា អូនឯងមុខជាពុំហ៊ានធ្វើអញ្ចឹងជាដាច់ខាតណាអូន...

— ម៉េចក៏បងគិតថាខ្ញុំពុំហ៊ានធ្វើ?



— ព្រោះបើអូនធ្វើអញ្ចឹងទៅ ក៏ទុកដូចជាអូនឯងបើកកកាយខ្ញូវការពិតប្រាប់ប៉ូលិសថា ប៉ានិងបងបានរួមគំនិតគ្នាធ្វើឃាតកម្មនោះ អូនឯងសុខចិត្តឲ្យប៉ានិងបងជាប់គុកឬ?...

— ខ្ញុំពុំប្រាប់ដល់អ្នកណាទេ! ខ្ញុំគ្រាន់តែប្រាប់ដល់ប្រពន្ធរបស់ខ្ញុំតែម្នាក់ប៉ុណ្ណោះ!...

— ហ្នឹងហើយ! បើអូនឯងប្រាប់រឿងនេះឲ្យគេដឹង គេក៏មុខជាខឹងនឹងប៉ានិងបងជាខ្លាំង ព្រោះប៉ានិងបងបានទៅពង្រាត់ប្ដីគេ — អូនឯងទុកចិត្តទុកថ្លើមគេយ៉ាងម៉េចបាន កាលបើគេខឹងដល់ចិត្តគេមែនទែន គេមុខជាទៅប្ដឹងប៉ូលិសពុំខាន ។

ពិតណាស់ហើយ ផែនការនេះ ជាផែនការដែលលោកឪពុក និង បងប្រុសរបស់ខ្ញុំបានគិតទុកយ៉ាងហ្មត់ចត់ណាស់ ហើយទើបលោកនាំគ្នាធ្វើដោយជឿជាក់ថា ខ្ញុំមុខជាពុំធ្វើអ្វីផ្ដេសផ្ដាសដែលជាហេតុនាំឲ្យការគាថកំបាំងនេះលេចឮខ្ចរ-ខ្ចាយឡើយ ព្រោះថា បើខ្ញុំធ្វើដូច្នោះទៅក៏ទុកដូចជាខ្ញុំសម្លាប់

លោក ។ ម្យ៉ាងទៀតការនេះ សូម្បីខ្ញុំបានត្រឡប់មកដល់ភ្នំពេញវិញហើយ ខ្ញុំក៏ពុំហ៊ានទាក់ទងអ៊ីចឹងនាង យូរ៉េត ទៀតឡើយ ឬសូម្បីបើទុកជាខ្ញុំបានត្រឡប់ទៅក្រុងបាងកកវិញ ក៏ខ្ញុំពុំអាចទៅរកនាងហើយនៅរួមរ័កជាមួយនាងបានទៀតឡើយ ព្រោះខ្លាចបែកការថា លោកឪពុកនិងបងប្រុសរបស់ខ្ញុំបានធ្វើនូវអំពើឃាតកម្មនុះ ។

វិធីនេះ ជាវិធីអាថ៌កំបាំងជ្រាលជ្រៅណាស់ ជ្រាលជ្រៅដែលពុំគួរជាឪពុក និងបងប្រុសរបស់ខ្ញុំ នាំយកទៅប្រើក្នុងករណីយដូចជារឿងរបស់ខ្ញុំនេះសោះ ហើយឪពុកនិងបងប្រុសរបស់ខ្ញុំ ក៏ពុំគួរជាធ្វើឲ្យរឿងនេះ ក្លាយទៅជារឿងរ៉ាំរ៉ៃធំដុំដល់ទៅប៉ុណ្ណោះសោះឡើយ ។

– ចុះសំបុត្ររបស់ខ្ញុំ ? (ខ្ញុំសួរ) សំបុត្រដែលខ្ញុំសរសេរផ្ញើទៅឲ្យប្រពន្ធខ្ញុំនោះ ? ...,

– បងហែកចោលទៅហើយ ! ហែកចោលអម្បាញ់



មិញនេះឯង ...

ការនេះក៏រឹតតែអាក្រក់លាមកណាស់ទៅទៀត ... ខ្ញុំខឹងខ្លាំងណាស់ កំហឹងនិងសេចក្ដីទុក្ខ កាលបើផ្ទុះឡើងព្រមគ្នា វាក៏កើតទៅជាសភាពនៃចិត្តដ៏ចម្លែកម្យ៉ាងខុសធម្មតា ដែលខ្ញុំពុំដឹងជាគប្បីរៀបរាប់ថាដូចម្ដេចឲ្យបានត្រូវ ... ខ្ញុំគិតថា ប្រសិនបើការពន្រ៉ាស់មកដោយស្ងៀម ៗ ដោយបណ្ដោយឲ្យខ្ញុំបានប្រាប់ដំណឹងដល់នាង យូរ៉េត ដូចសេចក្ដីនៃសំបុត្រដែលខ្ញុំបានសរសេរផ្ញើទៅឲ្យនាងនោះ ក៏ដូចជាទៅល្អជាងការធ្វើដូច្នេះបន្តិច ... តែនេះ លោកបានធ្វើឲ្យនាង យូរ៉េត ពុំដឹងជាមានសេចក្ដីទុក្ខសោកក្រៀមក្រំយ៉ាងណាទេ ? ... ហើយសេចក្ដីទុក្ខសោកក្រៀមក្រំនោះ នឹងមានទំហំធំប៉ុណ្ណាទៅ ? ... ការដែលឪពុកនិងបងប្រុសរបស់ខ្ញុំធ្វើដូច្នេះ ក៏ទុកដូចជាលោកបានសាងនូវស្ពាននៃសេចក្ដីទុក្ខសោកក្រៀមក្រំឲ្យស្ត្រីម្នាក់ដែលគ្មានកំហុសដើរ ... ខ្ញុំបានស្រឡាញ់

នាង ធ្វើឲ្យនាងព្រាត់ប្រាសនិរាសចេញពីស្រុកទេស និងញាតិសន្តានសាច់សាលោហិត ហើយទីបំផុតប្ដីបណ្ដូលចិត្តរបស់នាងក៏ត្រូវមានគ្រោះថ្នាក់ស្លាប់ – ស្លាប់ដោយឧបទ្ទវហេតុដែលពុំបានដានឹកនា – ស្លាប់ក្នុងពេលដែលនាងបានផ្ដែផ្ដាំឲ្យទិញរបស់សំរាប់ក្មេងលេងយកទៅផ្ញើកូនផង ...

ខ្ញុំលែងនិយាយស្ដីថាអ្វីតទៅទៀត ព្រោះដូចជាណែនដើមករកនិយាយអ្វីពុំរួច ... បងប្រុសរបស់ខ្ញុំ ក៏ដូចជាដឹងថា ខ្ញុំខឹងសម្បានឹងរូបចិត្តរូបថ្លើមនឹងលោក ...

យន្តហោះ ក៏បានមកដល់ចំណតអាកាសយានពោធិ៍ចិនតុង ហើយកំពុងតែបន្ទាបខ្លួនចុះ – យើងក៏បានប្រុងប្រៀបរៀបចំខ្លួនប្រាណដែរ ។

នៅពេលចេញពីក្នុងចំណតអាកាសយានមកខាងក្រៅ ខ្ញុំបានឃើញប្អូន ៗ របស់ខ្ញុំ គេនាំកូនប្រពន្ធរបស់គេមកចាំទទួលខ្ញុំ ។



គ្រាន់តែចុះឃើញកូនគេ (ក្មួយរបស់ខ្ញុំ) ខ្ញុំក៏ដូចជាស្លុតខ្លោចចិត្តជាខ្លាំង ព្រោះនឹកដល់កូនរបស់ខ្ញុំ ... ទេះដូងរបស់ខ្ញុំដូចជាដើរញាប់ខុសធម្មតា ... ក្បាលរបស់ខ្ញុំដូចជាធ្ងន់ធេងធោង ... ខ្ញុំងងឹតមុខស្លុប ... ក្រោយពេលដែលអ្នកខ្លះដំកបសួរ – អ្នកខ្លះឱបខ្ញុំបន្តិចមក ខ្ញុំក៏ខំដើរទៅរករថយន្តជារបស់ប្អូនខ្ញុំដែលចតចាំនៅខាងក្រៅ ដោយទប់ខ្លួនកុំឲ្យដួល ... តែខ្ញុំនៅចាំបានថា ខ្ញុំទើបតែបើកទ្វាររថយន្តនៅពុំទាន់បានឡើងជិះផង ខ្ញុំក៏លែងដឹងអ្វីតទៅទៀតទាំងអស់ ។

# វគ្គទី ១៦

# ជីវិតថ្មី

ខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ ក្នុងខណៈដែលខ្ញុំដេកនៅលើឥដ្ឋជិតគ្រែក្នុងបន្ទប់ដេករបស់ខ្ញុំ... ខ្ញុំសំឡឹងមើលពិតាន មើលជញ្ជាំង មើលតុទូនៃបន្ទប់ ៗ ខ្ញុំក៏នៅចាំបានយ៉ាងពិតប្រាកដថា បន្ទប់នេះ ជាបន្ទប់ដែលខ្ញុំធ្លាប់ដេកមកតាំងពីដើម... នេះ ខ្ញុំស្រមៃ ឬ យល់សប្តិ?... ក៏អាចដូច្នោះបានឬ ដែលខ្ញុំសន្លប់បាត់ស្មារតីតាំងពីពេលឡើងជិះរថយន្តពីចំណតអាកាសយានពោធិចិនតុងមក?...? នេះជារឿងដែលពុំគួរជឿសោះឡើយ... ខ្ញុំប្រហែលជាស្រមៃ ឬ យល់សប្តិទេមើលទៅ?...

ខ្ញុំធ្មេចភ្នែកទៅវិញ ដោយគិតថា ប្រសិនបើខ្ញុំស្រមៃ ឬក៏យល់សប្តិ ក៏ទុកឲ្យការស្រមៃឬយល់សប្តិតទៅទៀតចុះ... ប៉ុន្តែនេះ ខ្ញុំពុំមែនជាស្រមៃ ឬក៏យល់សប្តិអ្វីទេ... ខ្ញុំក៏ពុង ភ្ញាក់ដឹងខ្លួនហើយបើកភ្នែកស្រស់ ៗ ទទេ...



ខ្ញុំស្ទុះក្រោកឡើងហើយពិនិត្យមើលសព៌ាង្គកាយ ក៏ឃើញនៅស្រួលដូចដើម គ្មានស្លាកស្នាមអ្វី... អាវដែលខ្ញុំស្លៀកពាក់ទៀតសោត ក៏ស្អាតបាត... ខ្ញុំពិនិត្យមើលបន្ទប់ម្តងទៀត គឺឃើញថាជាបន្ទប់របស់ខ្ញុំពិតប្រាកដមែន... តែបន្ទប់នោះឥឡូវនេះ មានការប្លែកពីរយ៉ាងគឺ ម្យ៉ាងបង្អួចដែលពីដើមគ្មានចំរឹងដែក ឥឡូវមានចំរឹងដែកយ៉ាងមាំទាំ ហើយម្យ៉ាងទៀតក្នុងបន្ទប់នោះ ពីមុនមានគ្រឿងតាំងជាច្រើន តែឥឡូវនេះបាត់អស់រលីង ពុំដឹងជាអ្នកណាយកទៅណាអស់...

ខ្ញុំដើរតម្រង់ទៅមាត់ទ្វារ ដើម្បីបើកចេញទៅខាងក្រៅ តែទ្វារនោះត្រូវគេបិទសន្ទះជិតជាប់ ដែលមើលទៅដូចជាមានគេចាក់សោ ឬ ដាក់គន្លឹះខ្ទប់ពីខាងក្រៅ ៗ ខ្ញុំដើរទៅត្រង់មាត់បង្អួច ហើយសំឡឹងមើលទៅសួនច្បារនៅក្នុងបរិវេណរបងផ្ទះ ក៏ឃើញមានលក្ខណៈដូចដើម ៗ នេះជាអ្វី?

ជាផ្ទះរបស់ខ្ញុំ ឬ ពុំមែនទេ ? នេះពិតជាផ្ទះរបស់ខ្ញុំ ផ្ទះរបស់ឪពុកម្ដាយខ្ញុំ តែអ្វីគ្រប់បែបគ្រប់យ៉ាង មើលទៅដូចជាមានសភាពទ្រុឌទ្រោមជាងមុន ។ ដើមឈើដែលខ្ញុំធ្លាប់ឃើញតូចៗពីមុនមក ឥឡូវនេះវាក៏ស្ទុះធំសន្ធឹក ។ សភាពយ៉ាងនេះ ដូចជាពុំគួរជឿថា គ្រាន់តែពេលជាងបីឆ្នាំដែលខ្ញុំពុំនៅប៉ុណ្ណោះ ផ្ទះនេះក៏ទ្រុឌទ្រោម ហើយដើមឈើក៏ធំដល់ប៉ុណ្ណោះណោះឡើយ ។

ខ្ញុំក៏ដើរទៅរកមាត់ទ្វារម្ដងទៀត ។ ខ្ញុំគោះទ្វារប៉ុកៗច្រើនដង ហើយក៏ចាំស្ដាប់មើលថា មានអ្នកណាមកបើកទ្វារដែរ ឬ ក៏គ្មាន ។

— ប៉ា! ប៉ា! សំឡេងនេះ ជាសំឡេងក្មេងស្រី តែខ្ញុំក៏ពុំដឹងថាជាសំឡេងអ្នកណា ហៅអ្នកណាឡើយ) លោកពូគោះទ្វារទៀតហើយ! ..

— ស្រេចនឹកទៅចុះ! (នេះជាសំឡេងឆ្លើយឡើង



ជាសំឡេងដែលខ្ញុំល្មមនៅចាំបានថា ជាសំឡេងបងប្រុសរបស់ខ្ញុំ) កុំរវល់អីនឹងក!...

ខ្ញុំគោះទ្វារប៉ុកៗម្ដងទៀត ហើយម្ដងនេះ ខ្ញុំគោះខ្លាំងនឹងយូរជាងមុន ។

— ប៉ា! ប៉ា! (ខ្ញុំបានឮសំឡេងដដែលនោះទៀត) ។ មួយសន្ទុះក្រោយមក ខ្ញុំក៏បានឮសំឡេងបងប្រុសរបស់ខ្ញុំ ដែលនិយាយប្រាប់នឹងមាត់ទ្វារថា :

— គ្រាន់បើប្អូនដប់ថ្ងៃមកហើយ ចុះឥឡូវក៏យ៉ាងម៉េចទៀតហើយ ...

ខ្ញុំគោះទ្វារទៀត ។ បងប្រុសរបស់ខ្ញុំក៏ចាក់សោបើកទ្វារចូលមក ។

នេះជាបងប្រុសរបស់ខ្ញុំពិតប្រាកដមែន តែដូចជាចាស់ជាងមុន — លោកឈរនៅត្រង់មាត់ទ្វារសំឡឹងមើលមុខខ្ញុំមួយសន្ទុះទើបនិយាយថា :

– ហ៎ ! ចុះក្បាលអូនឯងទៅប៉ះនឹងស្អីទៀតហើយ ?

តាមពិត ខ្ញុំក៏ដូចជាដឹងថាឈឺត្រង់ក្បាលបន្តិចៗដែរ តាំងពីពេលដែលភ្ញាក់ពីដេក ។ លុះបងប្រុសខ្ញុំនិយាយដូច្នោះ ខ្ញុំក៏យកដៃស្ទាបក្បាលមើល ឃើញមានឈាមប្រឡាក់ជាប់ដៃ ។

– ឯងបានគ្រោះមកបួនដប់ថ្ងៃហើយ (បងប្រុសខ្ញុំនិយាយឡើងទៀត) ចុះឥឡូវយ៉ាងម៉េចទៀតហើយ . . .

ខ្ញុំពុំឆ្លើយថាអ្វី ! ព្រោះខ្ញុំឋិតនៅក្នុងសភាពសង្ស័យ ដែលមើលទៅដូចជាឃើញលាំងៗ ថា ហេតុការណ៍ដូចម្តេចខ្លះ ? . . . ខ្ញុំអាចក្លាយខ្លួនទៅជាមនុស្សដែលចរិតអស់ពេលច្រើនឆ្នាំក៏ពុំដឹង ? ខណៈនោះ បងប្រុសខ្ញុំបានយកថ្នាំ និងសំឡីមកលាបហើយបិទឲ្យខ្ញុំ ។

– បង ! (ខ្ញុំនិយាយដោយខំធ្វើសំឡេងឲ្យបានដូចធម្មតា) ខ្ញុំកើតអី ឬ បង ?

– ក្បាលរបស់ឯងបែក ! (បងខ្ញុំឆ្លើយ) អូនឯងប្រហែល



ជាយកក្បាលទៅផល់នឹងគ្រែហើយមើលទៅ បានជាវាបែកកញ្ចឹង

– ចុះម្តាយឪពុកញ៉ុមទៅណា ?

– ចេះតែសួរដដែល ៗ – ប្រាប់ស្ទើររហែកមាត់ហើយថា លោកស្លាប់យូរណាស់ទៅហើយនៅតែសួរទៀត

– លោកស្លាប់ប៉ុន្មានឆ្នាំហើយ ?

– ចុះបងឯងយកខ្ញុំមកពីបាងកកប៉ុន្មានឆ្នាំហើយ ?

លុះខ្ញុំសួររឿងនេះ បងប្រុសខ្ញុំ ក៏សំឡឹងមើលមុខខ្ញុំ ហើយចេះលូកដៃមកអង្អែលស្មាខ្ញុំ ។

– អូន ! អូនឯងជាហើយ ឬ ?

– ចុះខ្ញុំមានឈឺអីបង ?

– អូនឯងឆ្កួតអស់ពេលបីឆ្នាំមកហើយ

– ចាប់ផ្តើមឆ្កួតតាំងពីពេលណាមកបង ?

– តាំងពីពេលចុះពីយន្តហោះ – ពេលនោះអូនឯងដួល

ប៉ះក្បាលទៅនឹងក្តារខៀន ហើយសតិវិបល្លាសផ្តេសផ្តាស អស់ — ប៉ុន្តែនិងបងព្រមតាំងប្អូន ។ តាំងអស់ខំមើលអ្នកឯង យ៉ាងណាក៏ពុំជា ចុះឥឡូវម៉េចក៏អ្នកឯងបានជាដូចដើមវិញ អញ្ចឹង ?

— ពុំដឹងជាយ៉ាងម៉េចទេបង ប្រហែលដោយសារខ្ញុំដួល ប៉ះក្បាលទៅនឹងគ្រែ សរសៃខួរក្បាលក៏ត្រឡប់ចូលទៅកន្លែង ដើមវិញមើលទៅ

— អើ ! ប្រហែលជាអញ្ចឹងមែនហើយមើលទៅ

ខ្ញុំជឿពិតប្រាកដថាដូច្នេះមែន បានជាខ្ញុំជាសះស្បើយ ។ ខ្ញុំធ្លាប់បានអានសៀវភៅផ្សេង ៗ ហើយខ្ញុំធ្លាប់បានជួបប្រទះ នឹងករណីយដូចគ្នានឹងខ្ញុំ ។ មនុស្សជាលាធម្មតា បើក្បាល ទៅប៉ះទង្គិចនឹងអ្វីខ្លាំង ឬ ក៏ត្រូវគេវាយខ្លាំង សរសៃខួរក្បាល ក៏កំរើកឃ្លាតចេញពីកន្លែងដើម ហើយមនុស្សនោះក៏ឆ្កួតលីលើ លែងដឹងអ្វី ក្លាយទៅជាមនុស្សមានសតិវិបល្លាស ប៉ុន្តែបើ



ក្បាលអ្នកនោះទៅប៉ះទង្គិចនឹងអ្វីម្តងទៀត ហើយគាប់ជួនជាប៉ះ ទង្គិចត្រូវត្រង់កន្លែងចាស់នោះ ក៏អាចធ្វើឲ្យសរសៃខួរក្បាល ដែលកំរើកឃ្លាតចេញទៅនោះ ត្រឡប់ចូលមកត្រង់កន្លែង ដើមវិញ ហើយអ្នកនោះក៏ត្រឡប់ជាបានជាលាដឹងខ្លួនប្រាណ តាមធម្មតា ឬក៏មានសភាពជាប្រក្រតីដូចដើមវិញ ។ ឯព្រឹត្តិ-ការណ៍របស់ខ្ញុំក៏មុខជាដូច្នោះដែរ ។

— ចុះសំឡេងក្មេងស្រីដែលស្រែកហៅបងអម្បាញ់មិញ នេះជាសំឡេងអ្នកណា ?

— គាឡា ! (បងប្រុសរបស់ខ្ញុំឆ្លើយ) ក្មួយរបស់អូនឯង ហ្នឹងណា៎ !

— មើល ! សុំមើលមុខបន្តិចមើល ។

បងប្រុសខ្ញុំ បាននាំខ្ញុំចេញទៅខាងក្រៅ, ខ្ញុំបានជួប នឹងមនុស្សជាច្រើន ដែលខ្ញុំអាចស្គាល់បានភ្លាមថា ជាក្មេង ដែលខ្ញុំធ្លាប់បានឃើញកាលពីវានៅតូច ៗ ។ ខ្ញុំវិកលចរិត

អស់ពេលបីឆ្នាំ ៗ ខ្ញុំគិតថា បើពួកក្មេងៗដែលត្រូវជាក្មួយរបស់ខ្ញុំ ធំប៉ុណ្ណោះទៅហើយ ម្ល៉េះសមកូនរបស់ខ្ញុំគង់ពេលនេះក៏ធំក្រៃលែងដែរ ព្រោះបើគិតមកដល់ថ្ងៃនេះ យុរ៉ា ត្រូវមានអាយុបីឆ្នាំប្រាំបីខែហើយ ៗ ឯ យុរ៉េត ដែលខ្ញុំទុកដល់មុនគេ នៅពេលដែលខ្ញុំបានជំនួនក្រោណឡើងវិញនោះ ឥឡូវនេះ នាងត្រូវមានអាយុ ២៧ ឆ្នាំ ៗ ការនេះដូចជាពុំគួរជឿថា នឹងប្រព្រឹត្តទៅដូច្នេះសោះឡើយ ព្រោះខ្ញុំដូចជានៅតែថ្មីៗថា ពីម្សិលមិញនេះឯង ដែលទុកខ្ញុំនឹងបងប្រុសខ្ញុំបានបង្ខិតបង្ខំខ្ញុំឲ្យឡើងជិះយន្តហោះ ហើយបានអានសារពត៌មានដែលផ្សាយនូវដំណឹងនៃការស្លាប់របស់ខ្ញុំ ដែលខ្ញុំនៅចាំយ៉ាងជាក់ច្បាស់ ៗ

— ឆ្នាំនេះ គ.ស. ប៉ុន្មាន ? (ខ្ញុំសួរ)

— ឆ្នាំ ១៩៦២ (បងប្រុសខ្ញុំឆ្លើយ) ឆ្នាំនេះសមាគមអ្នកនិពន្ធខ្មែរកំពុងតែប្រកាសបើកសម័យប្រឡងប្រជែងអក្សរ



សាស្ត្រ ឈ្មោះរង្វាន់អីទេ ?

— រង្វាន់ឥន្ទ្រទេវី លើកទី ២ ៗ

ខ្ញុំដូចជាព្រឺខ្លួនញាក ព្រោះខ្ញុំចង់សរសេររឿងរ៉ាវរបស់ខ្ញុំយកទៅប្រឡងប្រជែង ៗ

— បង (ខ្ញុំនិយាយ) ខ្ញុំដូចជាចង់សរសេររឿងរ៉ាវរបស់ខ្ញុំយកទៅប្រឡងប្រជែងនឹងគេដែរ ! ...

— ល្អហើយអូន បងជឿជាក់ថា បើអូនសរសេរជាក់បាន មុខជាបានទទួលរង្វាន់លេខ ១ ខាងផ្នែកប្រលោមលោកជាពុំខាន ៗ

— តែក្រែងពុំដល់គេណាបង ព្រោះអ្នកនិពន្ធដែលមានឈ្មោះល្បីច្រើនណាស់ ៗ

ទេ ! មិនមែនទេ ! បងជឿជាក់ថា អ្នកទាំងនោះសរ-សេរមិនឈ្នះអូនទេ ព្រោះគេគ្រាន់តែជាអ្នកនិពន្ធដែលប្រឌិតរឿងរ៉ាវឡើងតែប៉ុណ្ណោះ — ឯអូនវិញ ពុំមែនប្រឌិតរឿងតាម

មនោគតិទេ អ្នកសរសេរទៅតាមរឿងក៏ពិតនៃជីវិតរបស់អ្នកឯង — ចង់ជឿជាក់ថា រឿងរបស់អ្នកឯងមុខជាឈ្នះគេទាំងអស់យ៉ាងពិតប្រាកដ — ព្រោះអ្នកមានឈ្មោះល្បីខាងសរសេរពិរោះហើយមានន័យ សូម្បីតែក្នុងកាសែត «ឈាមខ្មែរ», «កម្ពុជា», សង្គមរាស្ត្រនិយម, អ្នកជាតិនិយម ។ល។ ដែលអ្នកបានសរសេរផ្សាយ ក៏មហាជនទូទៅនិយមគាំទ ហើយសរសើរពុំដាច់មាត់ ហើយម្យ៉ាងទៀត អ្នកធ្លាប់មានថ្វីដៃផង ដូចជាកាលឆ្នាំ ១៩៥៧ ក្នុងឱកាសពិធីបុណ្យរំលឹក ២៥០០ វស្សា នៃព្រះពុទ្ធសាសនា អ្នកបានប្រឡងជាប់បានរង្វាន់ខ្ពង់ខ្ពស់ទៅហើយ ៗ សរសេរទៅអ្នក ៗ

ខ្ញុំអង្គុយគិត ខ្ញុំបានសំរេចចិត្តថា ត្រូវសរសេររឿងនេះ យកទៅរួមក្នុងការប្រឡងប្រជែង ប៉ុន្តែដើម្បីឲ្យរឿងនេះមានសភាពច្បាស់លាស់ពិរោះពិសា ខ្ញុំត្រូវទៅរកប្រពន្ធនិងកូនរបស់ខ្ញុំសិន ដើម្បីបន្ថែមឲ្យបានចប់ចុងចប់ដើម —



ខ្ញុំគិតថា ឥឡូវនេះប្រពន្ធនិងកូនរបស់ខ្ញុំពុំដឹងជាយ៉ាងណាទៅហើយ ៗ — តាមព្រឹត្តិការណ៍ក្នុងគ្រួសារ ឃើញថាមានសភាពស្រួលជាងមុន តាមសេចក្តីសង្កេតរបស់ខ្ញុំ ឃើញថាពេលនេះ បងប្រុសខ្ញុំក៏មានចិត្តអាណិតអាសូរចំពោះខ្ញុំជាខ្លាំង ។ នៅពេលដែលខ្ញុំបានដឹងខ្លួនប្រាណឡើងវិញ លោកបាននិយាយប្រាប់ខ្ញុំថា ឪពុកខ្ញុំបានចែកទ្រព្យសម្បត្តិឲ្យខ្ញុំជាច្រើន ហើយបងខ្ញុំបានកាន់កាប់ថែរក្សាជំនួសខ្ញុំរហូតមកដល់សព្វថ្ងៃ ។

## វគ្គទី ១៧

# ខ្ញុំមានទោស

ចំណែកខាងរឿងប្រពន្ធកូនរបស់ខ្ញុំនោះ បងប្រុសខ្ញុំបាននិយាយប្រាប់ខ្ញុំថា លោកពុំដែលបានទទួលដំណឹងអ្វីសោះឡើយ ។ ខ្ញុំតបបងខ្ញុំថា ជាការចាំបាច់ណាស់ដែលខ្ញុំត្រូវទៅរក ។ ប៉ុន្តែខ្ញុំបានសន្យាជាមួយបងខ្ញុំថា ខ្ញុំនឹងពុំបង្ហាញខ្លួនឲ្យអ្នកណាឃើញ ឬដឹងថា ខ្ញុំនៅមានជីវិតរស់នៅឡើយ ដែលជាហេតុធ្វើឲ្យមានការសើរើដល់រឿងឃាតកម្ម កាលពីបីឆ្នាំកន្លងមកហើយនោះ សាជាថ្មីឡើងទៀតទេ ព្រោះរឿងឃាតកម្មមានអាយុដល់ទៅម្ភៃ (២០) ឆ្នាំទើបរលត់ ។ ខ្ញុំបានតបបញ្ជាក់ថា សូមឲ្យលោកជឿខ្ញុំចុះ ក្នុងការដែលខ្ញុំត្រូវតាមទៅរកប្រពន្ធ – កូនវិញនោះ ខ្ញុំនឹងត្រូវធ្វើដោយការប្រយ័ត្នប្រយែងជាទីបំផុត ដើម្បីកុំឲ្យមាន



ការសើរើដល់រឿងចាស់ឡើងវិញ ។

លុះបានទទួលនូវសេចក្តីអនុញ្ញាតពីបងប្រុសខ្ញុំរួចហើយ ខ្ញុំក៏បានធ្វើដំណើរចេញទៅប្រទេសសៀមម្តងទៀត ហើយទីបំផុតខ្ញុំក៏បានទៅដល់ទីក្រុងបាងកក ។

រឿងដែលខ្ញុំត្រូវបិទបាំងពុំឲ្យអ្នកណាដឹងថា ខ្ញុំនៅមានជីវិតរស់នៅឡើយនោះ ជាការសំខាន់ទីងចាំបាច់បំផុតសំរាប់រូបខ្ញុំ ព្រោះប្រសិនបើខ្ញុំសំដែងខ្លួនឲ្យគេឃើញ គេក៏អាចដឹងភ្លាមថា ខ្មោចដែលត្រូវភ្លើងឆេះពេលស្លាប់នៅក្នុងរថយន្តនោះ ពុំមែនជារូបខ្ញុំឡើយ ហើយរឿងរ៉ាវនោះក៏នឹងចូលទៅក្នុងឃាតកម្ម ព្រោះហេតុការណ៍បែបនេះ ពុំមែនជារឿងរ៉ាវថ្មីដែលទើបមានម្តងពីរដងឡើយ ។ រឿងរ៉ាវបែបនេះធ្លាប់មានរឿងពិតនៅអឺរ៉ុបរួចមកហើយ ។ រឿងពិតនោះគឺមានបុរសម្នាក់ បានទៅធានាជីវិតខ្លួនទុកក្នុងក្រុមហ៊ុនមួយជាប្រាក់ដ៏ច្រើន ។ បុរសនោះបានប្រើកលៗដោយបើកបររថ

យន្តរបស់គេទៅដុកមនុស្សស្លាប់ ហើយក៏លើកខ្មោចនោះដាក់លើរថយន្តរបស់គេ រួចហើយក៏ក្លែងធ្វើជាបើកបររថយន្តនោះទៅបុកគល់ឈើ ។ តពីនោះមក ក៏គេគូសឈើគូសដុតរថយន្តនោះចោល ដើម្បីឲ្យភ្លើងឆេះទាំងរថយន្តទាំងមនុស្ស ។ ឯរូបគេក៏គេចខ្លួនបាត់ទៅ ដោយទុកឲ្យប្រពន្ធទៅបើកយកប្រាក់សំណងពីក្រុមហ៊ុនធានាជីវិត ។ លុះបើកប្រាក់បានហើយ នាងជាប្រពន្ធនោះ ក៏ធ្វើដំណើរទៅជួបនឹងប្ដីនៅត្រង់កន្លែងណាមួយដែលគេបានសន្យានឹងគ្នា ដើម្បីនាំគ្នារត់ទៅនៅឯបរទេស ដោយជឿជាក់ថាប្រាក់ដែលក្រុមហ៊ុនធានាជីវិតសងមកនោះ មានចំនួនច្រើនល្មមចិញ្ចឹមជីវិតបានស្រួលនៅបរទេស តែទីបំផុតគេក៏ចាប់បាន ។ វិធីការដែលបងប្រុសខ្ញុំបានធ្វើនោះ មើលទៅក៏ប្រហែលជាចំឡងយកបែបពីរឿងនោះមកប្រើ ព្រោះមានសភាពដូចគ្នាបេះបិទ ។ ខ្ញុំបានធានាជីវិតទុកបីសែនបាទ ។ ឥឡូវនាង យូរ៉ែត



ប្រហែលជាទៅបើកយកប្រាក់នោះរួចទៅហើយ ។ ប្រសិនបើការនេះលេចឮឡើងថា ខ្ញុំនៅមានជីវិតរស់នៅឡើយទេនោះ មនុស្សទីមួយដែលប៉ូលិសត្រូវចាប់ គឺរូបខ្ញុំហ្នឹងឯង ព្រោះខ្ញុំមុខជាពុំហ៊ានឆ្លើយដាក់បងប្រុសខ្ញុំឡើយ ហើយខ្ញុំក៏ត្រូវជាប់ទោស ។ ដូច្នេះការធ្វើដំណើរក្ដី ការសំណាក់នៅក្នុងក្រុងបារីសក្ដី ខ្ញុំក៏ត្រូវតែធ្វើយ៉ាងលាក់លៀមជាទីបំផុត ។

ឯរឿងក្លែងខ្លួនពុំជាអ្វីទេ ព្រោះខ្ញុំធ្លាប់បានជំនឹងដល់កិច្ចការនៃស្នានខ្លួនយ៉ាងច្បាស់លាស់ណាស់ ដោយខ្ញុំធ្លាប់បានហែលម្ដងរួចមកហើយ ។ ដូច្នេះខ្ញុំនៅមានការសំខាន់តែម្យ៉ាង គឺត្រូវសម្ងំខ្លួនពួនអាត្មានៅក្នុងទីស្ងាត់ ដើម្បីកុំឲ្យជួបនឹងមនុស្សដែលធ្លាប់ស្គាល់គ្នា ។

ខ្ញុំបានលបទៅមើលផ្ទះ ដែលខ្ញុំធ្លាប់នៅរួមរស់ជាមួយនាង យូរ៉ែត ។ ខ្ញុំគិតថា ខ្ញុំពុំគួរនឹងចូលទៅបង្ហាញខ្លួន

ឲ្យនាង យូរ៉ែត ឃើញភ្លាមៗទេ ព្រោះប្រសិនបើខ្ញុំធ្វើដូច្នោះ ទៅនាងមុខជាភ័យភិត ហើយខ្ញុំពិនិយាយគ្នាស្ដាប់បាន នោះ ក៏មុខជាលេចឮដល់អ្នកដទៃជាពុំខាន ។ ខ្ញុំគិតថា ខ្ញុំគួរចូលទៅជួបនាងនៅពេលស្ងាត់ ដែលគ្មានអ្នកណានៅជាមួយនាង ឬក៏ពេលដែលអ្នកបំរើដេកលក់ ។

ដោយហេតុថា ខ្ញុំមានការចាំបាច់ត្រូវលាក់ខ្លួនពួនអាត្មា នៅក្នុងបន្ទប់សណ្ឋាគារដ៏តូចក្នុងពេលថ្ងៃនោះ ខ្ញុំក៏ត្រូវទៅលបមើលនាង យូរ៉ែត តែក្នុងពេលយប់ៗ ។

ខ្ញុំបានពួននៅត្រង់ទីកំបាំងលបមើលនាងពីខាងក្រៅ ។ ខ្ញុំបានឃើញនាង យូរ៉ែត ដែលខ្ញុំនៅចាំច្បាស់ – ឃើញក្មេងប្រុសម្នាក់ដែលខ្ញុំជឿជាក់ថាជាកូនរបស់ខ្ញុំ – ឃើញស្រីចំណាស់ម្នាក់ដែលខ្ញុំពុំធ្លាប់ស្គាល់ ប្រហែលជាស្រីបំរើដែលទើបមកនៅថ្មី ។ ខ្ញុំពុំអាចចូលទៅជួបនាងក្នុងផ្ទះនៅពេលនេះបានឡើយ ព្រោះក្រែងនាងភ័យភិតហើយស្រែកឡូឡា



ឡើង ។ ខ្ញុំគិតថា គួរទៅរកកន្លែងណាសរសេរសំបុត្រយកទៅហុចឲ្យនាងតែម្ដង ។ បើធ្វើដូច្នេះ នាងមុខជាពុំភ័យភិតអ្វីឡើយ ព្រោះនាងបានអានសំបុត្រមុន បើចូលទៅនិយាយផ្ទាល់មាត់តែម្ដង ក្រែងនាងភ័យតក់ស្លុត ដោយគិតថាជាបិសាចរបស់ខ្ញុំមកលងនាង ។

ព្រះចន្ទរះឡើងក៏ត្រចះត្រចង់ ។ ខ្ញុំគិតថា យប់នេះប្រហែលជាគ្មានបានផលអ្វីឡើយ ព្រោះត្រូវចាំសរសេរសំបុត្រសិន តែចិត្តមួយទៀតគិតថា គួរចាំលបមើលបន្តិចទៀតសិន ព្រោះខ្ញុំដូចជានឹកនាងនឹងកូនយ៉ាងខ្លាំង ។

មួយសន្ទុះក្រោយមក ខ្ញុំឃើញនាងបិទទ្វារផ្ទះ ហើយដើរចេញមកខាងក្រៅ ។ ខ្ញុំភ្ញាក់ផ្អើលក្ដុក ក្នុងខណៈដែលបានឃើញព្រឹត្តិការណ៍ដូច្នេះ ។ ខ្ញុំនឹកឆ្ងល់ថា នាងយូរ៉ែតទៅណាក្នុងពេលយប់ស្ងាត់នេះ? ហេតុអ្វីក៏នាងទៅតែម្នាក់ឯង ពុំយកកូនទៅជាមួយផង? នាង យូរ៉ែត ប្រហែលជាមានគូ

សង្សារថ្មីហើយទេដឹង ឬមួយក៏នាងដើររកស៊ីក្នុងផ្លូវពុំល្អ ។

ដោយសារមានការងឿងឆ្ងល់យ៉ាងនេះ ខ្ញុំក៏ចេះតែចាំលបមើលប្រពន្ធខ្ញុំតទៅទៀត ឬបើនិយាយម្យ៉ាងទៀតថា ប្រពន្ធរបស់ខ្មោចខ្ញុំ ។

តែនាងពុំបានទៅណាទេ ។ នាងដើរទៅជ្រុងខាងជើងផ្ទះ សំដៅទៅរកកូនទេព្តា ។ កូនទេព្តានេះ ខ្ញុំបានធ្វើឡើងដោយដៃខ្លួនឯង កាលពីពេលដែលខ្ញុំនៅជាមួយនាង ។ លុះទៅដល់ហើយ នាងដុតទៀនធូបដោតលើកូនទេព្តានោះ ហើយលុតជង្គង់លើកដៃប្រណម្យ ហើយសូត្រធម៌ ឬ គឺថាអ្វី ដែលខ្ញុំឮអ៊ូៗ តែស្តាប់ពុំច្បាស់ ។ ពេលនោះ ខ្ញុំយល់ដល់កិច្ចវត្តនៃប្រពន្ធសំឡាញ់របស់ខ្ញុំថា នាងមកសូត្រធម៌បួងសួងចំពោះគុណទេព្តា និងគុណបុណ្យព្រះរតនត្រ័យដើម្បីគោលបំណងអ្វីមួយ ។ លុះពិនិត្យឃើញថា ជាឱកាសល្អ ដោយគ្មានអ្នកណានៅជិត ខ្ញុំក៏ដើរចូលទៅរកនាង ។ នាងបែរមុខ



មកមើលខ្ញុំក្នុងខណៈដែលបានឮស្នូរជើងរបស់ខ្ញុំចូលទៅជិតៗ

— យូរ៉េត អូន! (ខ្ញុំហៅឈ្មោះនាងតិចៗ ដើម្បីកុំឲ្យនាងខ្លាច ឬ ភ័យភិត ហើយស្រែកឡូឡាឡើង) យូរ៉េត! បងមកវិញហើយ — បងនៅពុំទាន់ស្លាប់ទេ — ឥឡូវបងត្រឡប់មករក យូរ៉េត វិញហើយ ។

ពេលនោះ ជាគ្រោះល្អរបស់ខ្ញុំ! នាង យូរ៉េត គ្រាន់តែស្រឡាំងកាំង ពុំបានស្រែកឡូឡាឡើងឡើយ ... នាងញ័ររន្ធត់អស់ទាំងខ្លួនប្រាណ តែឥតមាននិយាយស្តីថាអ្វី ...

— បងទេតើ យូរ៉េត! (ខ្ញុំប្រញាប់និយាយតទៅទៀត) បងពុំមែនជាខ្មោចបិសាចអីទេ — បងជាប្តីរបស់ យូរ៉េត — ឯមនុស្សដែលស្លាប់នៅក្នុងឡាននោះ ពុំមែនរូបបងទេ — យូរ៉េត កុំខ្លាច — កុំភិតភ័យអី ចាំបងនិយាយរឿងរ៉ាវឲ្យ យូរ៉េត ស្តាប់ ។

— បង! (នាង យូរ៉េត និយាយដោយសំឡេងញ័រៗ

ព្រោះការរំភើបចិត្ត) បងទេឬ ?

— ហ្នឹងហើយ យូរ៉េត អូន! ប្តីរបស់អូនដែលធ្លាប់បានប្តេជ្ញាជាមួយអូនថា នឹងពុំព្រមឲ្យអំណាចអ្វីមួយក្នុងលោកមកពង្រាត់បម្រាសយើងចេញពីគ្នា ក្រៅពីសេចក្តីស្លាប់ ។

ប្រហែលជាដោយសារការដែលខ្ញុំនិយាយដល់ពាក្យគ្រង់នេះហើយ ដែលធ្វើឲ្យនាង យូរ៉េត ជឿជាក់ថា ជារូបខ្ញុំពិតប្រាកដ ព្រោះអ្នកដទៃពុំអាចដឹងនូវពាក្យប្តេជ្ញានោះឡើយ ។ នៅពេលដែលខ្ញុំបានពោលពាក្យនោះចប់ នាង យូរ៉េត ក៏ស្ទុះចូលមកឱបខ្ញុំហើយយំខ្សឹកខ្សួល ។ ក្នុងពេលនោះ ខ្ញុំក៏ក្លាយខ្លួនទៅជាកូនក្មេងទន់ខ្សោយ ព្រោះខ្ញុំពុំអាចទប់ទឹកភ្នែកពុំឲ្យស្រក់ជាមួយនាងបាន ។

ខ្ញុំឱបនាង ថើបនាង ដោយពុំចាំបាច់និយាយអ្វីនឹងគ្នា ។ នាង យូរ៉េត គ្មានអ្វីផ្លាស់ប្តូរប្រែប្រួល សូម្បីតែក្លិនក្រអូបដោយធម្មជាតិរបស់នាងក៏នៅដូចដើម ដែលខ្ញុំនៅចាំបាន ។



យើងអង្គុយនិយាយគ្នាត្រង់កន្លែងនោះ — និយាយគ្នានៅចំពោះមុខកនទេព្តាដែលនាងដំកល់ធាតុខ្មោចខ្ញុំ ។

ខ្ញុំបាននិយាយរឿងរ៉ាវទាំងអស់ប្រាប់នាង តាំងពីកាលដែលឪពុករបស់ខ្ញុំ បានបង្ខំឲ្យខ្ញុំឡើងជិះយន្តហោះ ហើយខ្ញុំក៏វិលខ្លួនភ្លេចអស់ពេលបីឆ្នាំ ។ ខ្ញុំបានអង្វរករនាងថា សុំកុំឲ្យនាងខឹងសម្បាអ្វីនឹងឪពុកក្មេកនាង ព្រោះឥឡូវលោកបានអនិច្ចកម្មទៅហើយ ។ ឯរូបខ្ញុំវិញនោះ ខ្ញុំសង្ឃឹមថា នាង យូរ៉េត មុខជាគ្មានការសង្ស័យថា ខ្ញុំបែកចិត្តពីនាង ឬក៏ធ្វើខុសពាក្យប្តេជ្ញាឡើយ ។

— អូនសង្ស័យខ្លះដែរ ថាមុខជាមានការអាថ៌កំបាំងអ្វីម្យ៉ាងនៅក្នុងរឿងនេះជាពុំខាន

— ចុះមានហេតុអ្វីដែលធ្វើឲ្យអូនសង្ស័យថាអញ្ចឹង ?

— ព្រោះកាលបើមានរឿងរ៉ាវកើតឡើងថា រូបបងត្រូវភ្លើងឆេះពេលស្លាប់នៅក្នុងយន្តហោះ, ក្នុងថ្ងៃជាមួយគ្នានោះ

ក៏មានរឿងមនុស្សបាត់ខ្លួនម្នាក់ដែរ គឺបាត់សូន្យឈឹងគ្មានលេចឮដំណឹងអ្វីសោះ ។

– ចុះពួកតម្រួតដែលហៅអូនទៅសាកសួរដែរឬ ?

– ចាស ! ធ្លាប់ហៅទៅសួរចំផងដែរ – ក្នុងពេលសាកសួរនោះ អូនសង្កេតឃើញថា តម្រួតសង្ស័យជាខ្លាំងថា មនុស្សអ្នករងគ្រោះស្លាប់នោះពុំមែនជារូបបងទេ – គេសង្ស័យលើរូបមនុស្សបាត់ខ្លួននោះ – តម្រួតបានសួរអូនថា ការនេះអាចប្រព្រឹត្តទៅយ៉ាងនោះបានឬទេ ថាបងបើកឡានទៅចុកមនុស្សនោះស្លាប់ ហើយក៏លើកខ្មោចនោះដាក់លើឡានយកទៅដុតចោលជាមួយនឹងឡាន ដើម្បីធ្វើឲ្យអូនជឿជាក់ថាបងស្លាប់ពិតប្រាកដមែន ហើយបងក៏រត់ចោលអូន ឬ បើមិនអញ្ចឹងទេ ក៏ជារឿងដែលបងនិងអូនរួមគំនិតគ្នា ដើម្បីទៅបោកយកប្រាក់ពីក្រុមហ៊ុនធានាជីវិត ។

– ចុះអូនឆ្លើយប្រាប់គេថាម៉េច ?



– អូនប្រកែកដាច់ខាតថា ពុំមែនអញ្ចឹងទេព្រោះបងស្រឡាញ់អូនណាស់ តែតម្រួតក៏ឆ្លើយមកវិញថា រឿងរបៀបនេះធ្លាប់មានច្រើនមកហើយ ...

– ចុះសំរាប់ យូរ៉េត វិញ តើអូនយល់យ៉ាងម៉េច ?

– អូនជឿជាក់ថា បងស្លាប់ពិតប្រាកដមែន – អូនពុំដែលគិតថា បងរត់ចោលអូនសោះ – ប្រសិនបើបងរត់ចោល បងមុខជាពុំធ្វើរបៀបនេះទេ ។

ខ្ញុំបានប្រាប់នាង យូរ៉េត ថា ខ្ញុំបានសំណាក់នៅក្នុងសណ្ឋាគារមួយ ហើយខ្ញុំមានលិខិតឆ្លងដែនថ្មី ប្រើឈ្មោះថ្មី ។ តែបើទុកជាយ៉ាងនេះក៏នាង យូរ៉េត នៅតែយល់ថា ពុំអាចរួចខ្លួនបាន ព្រោះមានគេស្គាល់ខ្ញុំច្រើនណាស់ ។ មិនតែប៉ុណ្ណោះនៅពេលកើតហេតុនោះ សារពត៌មានក៏បានដាក់រូបភាពរបស់ខ្ញុំផ្សាយផង ។ ដូច្នេះយើងត្រូវតែចេញពីក្រុងបាងកកយ៉ាងរួសរាន់ ហើយក្នុងចន្លោះពេលដែលយើងត្រូវ

រៀបចំចេញដំណើរនេះ ខ្ញុំត្រូវតែលាក់ខ្លួនពួនអាត្មាកុំឲ្យអ្នកណាឃើញ ។

– ចុះរឿងក្រុមហ៊ុនធានាជីវិតនោះយ៉ាងម៉េចទៅ ? គេបានសងប្រាក់ដល់អូនឬទេ ?

– សងហើយ ! សងគ្រប់តាមចំនួនដែលបងបានធានាជីវិតទុក ។

– ចុះកូនយើងយ៉ាងម៉េចខ្លះ អូន ?

– ស្រួលបួលទេ តែវាស្អាតបាតគួរឲ្យស្រឡាញ់ណាស់ ។

– ធ្វើម៉េចបានជួបមុខកូនបន្តិច ?

– កុំអាលជួបធ្វើអី

ជារៀងរាល់រាត្រី ខ្ញុំបានលបទៅជួបនាងយូវ៉េតហើយពិភាក្សាគ្នាពីការដែលយើងត្រូវរត់ចេញពីក្រុងបាងកក ។ នៅយប់ក្រោយនាង យូវ៉េត បានឲ្យដំណឹងពុំល្អដល់ខ្ញុំថា មានមនុស្សឃើញនាង និងខ្ញុំអង្គុយនិយាយគ្នាត្រង់កន្លែងនេះ ។



ពិតណាស់ ការដែលខ្ញុំលបទៅជួបនឹងនាង យូវ៉េត រាល់យប់នោះ គឺជាការពិបាកនឹងរួចផុតពីការសង្កេតរបស់អ្នកដទៃណាស់ តែក៏ជាគ្រោះល្អម្យ៉ាងដែរ ព្រោះអ្នកទាំងនោះយល់ថា រូបខ្ញុំនេះជាខ្មោចបិសាច ហើយដំណឹងនេះក៏បានលេចពុះខ្ចរខ្ចាយទៅជារឿងប្លែកពីរឿងធម្មតា ។

នាង យូវ៉េត បានយកសារពត៌មានមកបង្ហាញខ្ញុំ ឲ្យខ្ញុំមើលរឿងក៏វរបស់ខ្ញុំ ឬ បើនិយាយម្យ៉ាងទៀតថា រឿងបិសាចរបស់ខ្ញុំ ដែលក្លាយទៅជារឿងធំដុំក្នុងទំព័រកាសែត ។ នាង យូវ៉េត បានប្រាប់ខ្ញុំថា ពួកអ្នកកាសែតប្រះប្រែមករកគួននាង ដោយមកសុំធ្វើសម្ភាសន៍ សាកសួរនាង នាងបានឲ្យយោបល់ថា រឿងនេះបើត្រាំនៅយូរបន្តិចទៀត ក្រែងរឿងបិសាចនោះវារលត់ទៅ វាមុខជាលេចរឿងពិតក្រោកជារបស់ខ្ញុំវិញមិនលែង ។

ខ្ញុំបានព្រមព្រៀងគ្នាជាមួយនាងថា ខ្ញុំត្រូវធ្វើដំណើរចេញទៅចាំនាងឯអូរជ្រៅមុន ដោយនាងសន្យាថា នាងនឹងលបធ្វើដំណើរទៅតាមក្នុងរវាងពីបីថ្ងៃក្រោយ ។

លុះដល់ពេលកំណត់ នាង យូរ៉េត បាននាំកូនមកតាមខ្ញុំមែន ។ ក្នុងពេលនោះ ខ្ញុំរកនិយាយអ្វីពុំរួច ព្រោះភ័យផងអរផង ។ ការដែលខ្ញុំភ័យនោះ ក៏ព្រោះតែក្រែងមានគេឃើញគេដឹង ឯការដែលខ្ញុំអរនោះ ក៏ព្រោះបានជួបមុខកូនសំឡាញ់ ។ តែក្នុងពេលជួបនោះ យូរ៉ា កូនប្រុសរបស់ខ្ញុំសំឡឹងមើលមុខខ្ញុំឡើងឡង់ ៗ ដោយការខ្លាច ព្រោះវាពុំដែលស្គាល់ ។ មុខមាត់វាស្អាតដូចម្ដាយវាបេះបិទ ។ ម្ដាយវាលើកវាហុចមកឲ្យខ្ញុំ ។ ខ្ញុំទទួលយកមកបីថើប ហើយពេលនោះក៏ជាពេលដែលយើងទាំងអស់គ្នាចាប់ប្រើបទបាតនៃការសម្រក់ទឹកភ្នែក។ ខ្ញុំនិងនាង យូរ៉េត ស្រក់ទឹកភ្នែកក៏ព្រោះនឹកស្រណោះដល់



រឿងកំសត់នៃជីវិត ឯ យូរ៉ា យំនោះ ក៏ប្រហែលជាវាមិនដែលស្គាល់ខ្ញុំហើយវាខ្លាចខ្ញុំ ។

ខ្ញុំគិតថា ក្នុងការដែលខ្ញុំជួបជុំប្រពន្ធកូនក្នុងគ្រានេះ ជាការមិនងាកបញ្ចប់នូវរឿងរ៉ាវដ៏កំសត់ក្នុងជីវិតរបស់ខ្ញុំហើយ ...

ខ្ញុំមានបំណងតទៅអនាគតតែម្យ៉ាង គឺ សូមឲ្យខ្ញុំមានឱកាសបានធ្វើដំណើរការនៃជីវិតយ៉ាងស្ងប់ស្ងាត់ ប្រាសចាកការរុករួននៃអ្នកដទៃ ...

ខ្ញុំបាននាំប្រពន្ធកូនកំសត់ទៅនៅត្រង់កន្លែងមួយដ៏ស្ងាត់ ដែលខ្ញុំយល់ថាល្មមរួចខ្លួនពីការដែលមានគេស្គាល់ ... តែដោយសារការដែលខ្ញុំត្រូវការបិទបាំងអាសយដ្ឋានរបស់ខ្ញុំនោះ បានជាខ្ញុំនៅពុំទាន់ជំរាបឲ្យដឹងពិតប្រាកដថា សព្វថ្ងៃនេះខ្ញុំនៅឯណា ?

ខ្ញុំគ្រាន់តែសូមជំរាបថា ខ្ញុំតែងគិតថា រូបខ្ញុំសព្វថ្ងៃនេះជាអ្នកមានទោសឧក្រិដ្ឋ តែខ្ញុំដូចជារកគិតខ្លួនឯងពុំយល់ដែរ

ថា ការដែលខ្ញុំមានទោសនេះ តើខ្ញុំមានទោសព្រោះអ្វី? បើអ្នកដទៃក្រៅអំពីរូបខ្ញុំវិញ តើគេប្រព្រឹត្តទៅយ៉ាងណា? តើគាបចៀសរួចខ្លួនដែលខ្ញុំបានគេចមកនេះបានឬទេ? ។

ចប់

# កំណត់សំគាល់

"ខ្ញុំមានទោសព្រោះអ្វី" នេះ អ្នកនិពន្ធបានដាក់ជូនក្រសួងឃោសនាការពិនិត្យមុនចេញបោះពុម្ពផ្សាយ ។

ក្រសួងឃោសនាការ ដោយយល់ឃើញថា រឿងនេះមានការទាក់ទងនឹងកិច្ចការរបស់កងទ័ព ក៏បានបញ្ជូនទៅក្រសួងការពារប្រទេស ដើម្បីសុំយោបល់តាមលិខិតលេខ ១.៣៥២ ឃសក/កត ចុះថ្ងៃទី ៤-១២-៦៥ ។

ក្រសួងការពារប្រទេសបានពិនិត្យហើយ ពុំបានយល់ទាស់ទេ ចំពោះជំពូកទី ១ ឯជំពូកទី ២ ក្រសួងការពារប្រទេសបានស្នើសេចក្ដីករណី ដាក់ជូនឯកឧត្ដម ឧត្ដមសេនីយ នាយករដ្ឋមន្ត្រីពិនិត្យកាលពីថ្ងៃទី ២៨-១១-៦៦ ។

ទីស្ដីការនាយករដ្ឋមន្ត្រីបានអនុញ្ញាត ដោយឲ្យមានការកែប្រែខ្លះ តាមលិខិតលេខ១១៦០ នរម/សព ចុះថ្ងៃទី ១៤-២ ៦៧

ក្រសួងការពារប្រទេស បានអនុញ្ញាតតាមលិខិតលេខ ១៩៨ – ពឃ/ក ៤ ចុះថ្ងៃទី ១៧-៤-៦៧ ។

ក្រសួងឃោសនាការ បានអនុញ្ញាត តាមលិខិតលេខ ២៨៣ ឃសក/កព ចុះថ្ងៃទី ២១-២-៦៧ ។

ឈិញ-ម៉ាញ

# បញ្ជីរឿង

ជំពូកទី ១.–

វគ្គទី ១– រឿងតាចិកំបាំងបិទមុខ

វគ្គទី ២– ដើមហេតុនៃរឿង

វគ្គទី ៣- ចួនជាចួប

វគ្គទី ៤– អត្តឃាដកម្ម

វគ្គទី ៥ បែកគ្នាគ្រាលំបាក

វគ្គទី ៦– លាហើយស្នេហា

ជំពូកទី ២ –

វគ្គទី ៧– ការក្បត់ជាតិរបស់ខ្ញុំ

វគ្គទី ៨ ស្ត្រីជាសត្រូវ

វគ្គទី ៩– បំពេញបេសកកម្មពិសេស

វគ្គទី ១០– ការកាត់ទោសប្រហារជីវិត

វគ្គទី ១១– ឃាតកម្ម

វគ្គទី ១២– តើបក្រពត្តិបំបែកប្រទេសខ្មែរជាពីរបានឬ?

## ជំពូកទី៣.

វគ្គទី ១៣. តើឪពុកបំបែកកូនពីគូស្នេហាបានឬ?

វគ្គទី ១៤– កិច្ចការពិសេស

វគ្គទី ១៥– ទុក្ខព្រួយព្រោះព្រាត់

វគ្គទី ១៦– ជីវិតថ្មី

វគ្គទី ១៧– ខ្ញុំមានទោស